# មជ្ឈមណ្ឌលឯកសារកម្ពុជា

**ទឹម ផន ភេទប្រុស I05382**

**មុខងារៈ បុគ្គលិកក្រសួងការបរទេស**

**ជួបសម្ភាសជាមួយ ទឹម ផន អាយុ៨៨ឆ្នាំ ជាម្ចាស់ប្រវត្តិរូប**

**នៅភូមិតាយឹង ឃុំដំបូកខ្ពស់ ស្រុកបូរីជលសារ ខេត្តតាកែវ**

**ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៨**

**សម្ភាសដោយៈ ផេង ពង្សរ៉ាស៊ី**

**សរុបៈ ៣៧ទំព័រ**

**យោបល់អ្នកសម្ភាសន៍ៈ**

រ៉ាស៊ីៈ ចំពោះករណីនេះ ករណីម្ចាស់ប្រវត្តិរូបផ្ទាល់ដែលយើងជួបហ្នឹង បើតាមខ្ញុំមើល ទៅគាត់សម្ភាសន៍ មើលទៅរូបរាងរបស់គាត់ មើលទៅមុខមាត់របស់គាត់ហ្នឹងជាមនុស្សត្រង់ទេ ជាមនុស្សធម្មតា ។ ប៉ុន្តែដល់ពេលគាត់និយាយដូចមានចំណុចខ្លះ គាត់មានលាក់បាំង ។ តើវណ្ណះឯងយល់ម៉េចដែរ?

វណ្ណះ: មានចំណុចខ្លះ គាត់និយាយរឿងត្រង់ តែខ្លះទៀតគាត់និយាយដូចជាមានការលាក់ដែរដូចថា មានចំណុចខ្លះគាត់និយាយវៀង ដូចថា អ្នក ពីលើមកទទួលបញ្ហាចឹងទៅដល់ក្រោមដូចជាបាត់បញ្ហាខាងក្រោមទៀត ។

រ៉ាស៊ីៈ គាត់និយាយមិនសូវក្បោះក្បាយ ដូចថា របៀបថាភ្លេចភ្លាំងអាពេលវេលាដែលគាត់ធ្វើការច្រើនណាស់ ស្តាប់ទៅ ឧទាហរណ៍ដូចរឿង គាត់ថា គាត់ធ្វើឈ្លបឃុំប៉ុន្មានឃុំ ដូចរទៅធ្វើការនៅក្រសួងការបរទេសហ្នឹងប៉ុន្មានឆ្នាំ ។ ក្រោយមកគាត់ខូចសីលធម៌នៅឆ្នាំណា គាត់អត់ចាំទាំងអស់ ដល់ចឹងយើងពិបាកកំណត់ ពិបាកវាយតំលៃពិរយៈពេលនៃការងាររបស់គាត់ ប៉ុន្តែគាត់ដឹងច្បាស់ថា ពេលដែលគាត់ខូចសីលធម៌នៅចុងឆ្នាំ ជិតបែក គាត់ទៅជាប់នៅតាខ្មៅហ្នឹង៤ខែ ហើយបានចេញមកចូលធ្វើទាហាន ហើយវៃបែកហ្មង ។ ប៉ុន្តែគាត់ថាពេលដែលគាត់ជាប់នៅតាខ្មៅហ្នឹងខ្នងឆ្នាំ១៩៧៦ ។ ដល់ចឹងពេលវេលាវាពិបាកលៃវាពិ

បាកយល់តាមហ្នឹងណាស់ ។ ខ្ញុំគិតថា នៅចំណុចខ្លះគាត់នៅលាក់នៅឡើយ ។ គាត់ដូចថា នៅមិនទាន់ទុកចិត្តយើង ។

វណ្ណៈ ហ្នឹងហើយ មើលទៅឃើញចឹង មើលទៅឃើញថាគាត់អត់សូវ នៅមានការភ័យខ្លាច ។

រ៉ាស៊ី: មានអីទៀតទេ?

វណ្ណៈ អត់ទេ ។

រ៉ាស៊ី: ខ្ញុំទាំងពីរនាក់ហ្នឹងនាអង្គការក្រៅរដ្ឋាភិបាលមួយដែលសហការជាមួយជាមួយរដ្ឋាភិបាល យើង ធ្វើនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ៗ គឺជាកន្លែងដែលធ្វើទស្សនាវដ្ដីស្វែងរកការពិត ឲ្យតែការពិតពួកខ្ញុំចង់ដឹងទាំងអស់ ។ ហើ តួនាទីសំខាន់គឺចង់ប្រមែប្រមូលនូវឯកសារប្រវត្តិសាស្ត្រនានាដែលទាក់ទងនឹងប្រទេសកម្ពុជាយើងកាលពីសម័យខ្មែរក្រហម ជាពិសេសចង់ដឹងរឿងរ៉ាវដែលច្បាស់លាស់ដែលមិនលំអៀង ពីរបបខ្មែរក្រហមហ្នឹងពីថ្ងៃ១៧មេសាឆ្នាំ ១៩៧៥ រហូតដល់ថ្ងៃទី៦មករាឆ្នាំ១៩៧៩ ។ ហើ ពត៌មានដែលពួកខ្ញុំទទួលបានពីពូហ្នឹងខ្ញុំនឹងរក្សាសិទ្ធជូនពូ បើសិនជាពូមិនចង់ឲ្យពួកខ្ញុំនេះផ្សព្វផ្សាយនូវឈ្មោះរបស់ពូខ្ញុំធ្វើបាន ។ ហើពត៌មានដែលខ្ញុំទទួលបាននេះគឺខ្ញុំយកទៅបំរើជូនសាធារណជន ក៏ដូចជាសិស្សនិស្សិតទាំងឡាយឲ្យដឹង ឲ្យដឹងការលំបាករបស់យើងកាលជំនាន់ហ្នឹងយ៉ាងម៉េចខ្លះ ។ ដូចកូនលោកពូចឹង បើសិនជាពូអត់និយាយប្រាប់វាទេ វាអត់ដឹង ។

ផន: អត់ដឹងទេ ។

រ៉ាស៊ី: ដួនកាលពូនិយាយប្រាប់វាហើយ វាអត់ជឿ ៗ ថាជំនាន់ហ្នឹងលំបាកវេទនាម៉េច ។

ផន: លំបាកវេទនាប៉ុណ្ណាក៏វាអត់ដឹងដែរ ។

រ៉ាស៊ី: ដូចពូខំតស៊ូតាំងពីក្មេង ៗ រត់ចូលព្រៃ តែចុងបញ្ចប់ពូនៅដដែល នៅធ្វើស្រែចំការដដែលមានបានអី ។ វិតតែពិបាកជាងមុនផង ។ ចឹង ពូ យល់ពីគោលបំណងពីពួកខ្ញុំហើយ ។

ផន: បាទ!

រ៉ាស៊ី: ខ្ញុំគ្រាន់តែចង់បានពត៌មានដែលលំអៀងមួយខ្ញុំចង់ឲ្យពូនិយាយការពិតនូវអ៊ីដែលពូធ្លាប់ឆ្លងកាត់អ៊ីដែលពូធ្លាប់បានឃើញ ។ ខ្ញុំសួរទៅលោកពូនេះចង់ដឹងពីប្រវត្តិរបស់ពូហើយនឹងការអ៊ី

ដែលលោកពូបានឃើញ ។ ឧទាហរណ៍មានសំលាប់ត្រង់ណាម្នាក់ដែលពូបានឃើញពូប្រាប់ខ្ញុំ ខ្ញុំអត់សួរទាក់ទងអ្វីផ្សេងដល់ពូទេ ។ ចឹង ខ្ញុំចង់ស្គាល់ឈ្មោះពូ តើពូឈ្មោះអី?

ផន: ខឹម ផន ។

រ៉ាស៊ី: អាយុប៉ុន្មានហើយ?

ផន: អាយុ៤៨ឆ្នាំហើយ ។

រ៉ាស៊ី: លោកពូរស់នៅណាដែរ?

ផន: នៅភូមិត្រយឹង ។

រ៉ាស៊ី: ឃុំអីដែរ?

ផន: ឃុំដូងខ្ពស់ ។

រ៉ាស៊ី: ស្រុក?

ផន: ស្រុកបុរីជលសារ ។

រ៉ាស៊ី: កាលដាក់ក្នុងប្រវត្តិរូបដាក់ស្រុកទ្រាំង ។

ផន: ផ្លាស់ថ្មីហើយ ។

រ៉ាស៊ី: លោកពូមានគ្រួសារឈ្មោះអីដែរ?

ផន: ជា រុន ។

រ៉ាស៊ី: គាត់អាយុប៉ុន្មានហើយ?

ផន: ៤៧ហើយ ។

រ៉ាស៊ី: ប្អូនពូមួយឆ្នាំ?

ផន: បាទ!

រ៉ាស៊ី: សព្វថ្ងៃគាត់នៅរស់ទេ?

ផន: នៅរស់ ។

រ៉ាស៊ី: លោកពូមានកូនប៉ុន្មាននាក់ដែរ?

ផន: ខ្ញុំកូន១០នាក់ ។

រ៉ាស៊ី: ពូរៀបការឆ្នាំណា?

ផន: ឆ្នាំ១៩៧៩ ចុះពីលើមក ។

រ៉ាស៊ីៈ ឥឡូវចូលរៀនខ្លះធ្វើការខ្លះហើយ?

ផនៈ មិនទេចូលរៀន មានគ្រួសារ៣នាក់ ។

រ៉ាស៊ីៈ ចុះឪពុកម្តាយពូឈ្មោះអីដែរ?

ផនៈ សំ អិត ស្លាប់ហើយ ។

រ៉ាស៊ីៈ គាត់ស្លាប់នៅឆ្នាំណាដែរ?

ផនៈ ឪស្លាប់ខ្ទង់៨ឆ្នាំ ឪ១៩៨០ជាង ប៉ុនមិនដឹង ១៩៨០ប៉ុន្មាន ៧ឆ្នាំហើយ ។

រ៉ាស៊ីៈ គាត់ស្លាប់ដោយសារជំងឺ?

ផនៈ ដោយជំងឺ ។

រ៉ាស៊ីៈ ចុះម្តាយលោកពូឈ្មោះអីដែរ?

ផនៈ ឃិន ។

រ៉ាស៊ីៈ ត្រកូលគាត់?

ផនៈ ឌុក ឃិន ។

រ៉ាស៊ីៈ មិនមែន ជប់ ឃិន?

ផនៈ បាទ!

រ៉ាស៊ីៈ គាត់អាយុប៉ុន្មានហើយ?

ផនៈ ម៉ែដូអាយុ៧៦-៧៧ហើយ ។ ម៉ែអាយុ៧៧ឆ្នាំហើយ ។

រ៉ាស៊ីៈ គាត់រស់នៅសព្វថ្ងៃហ្នឹង?

ផនៈ នៅ ។

រ៉ាស៊ីៈ មិនទាន់ជរាទេ នៅដើរនៅធ្វើការបាន?

ផនៈ ទេ ម៉ែអត់មានធ្វើអីកើតសោះនៅដេកលើគ្រែ ។ ម៉ែចាស់ហើយគក់ផងអីផង ។

រ៉ាស៊ីៈ លោកពូមានបងប្អូនប៉ុន្មាននាក់ដែរ?

ផនៈ ខ្ញុំ៦នាក់ ។

រ៉ាស៊ីៈ លោកពូកូនទីប៉ុន្មានដែរ?

ផនៈ ខ្ញុំប៉ុន្មាប់ពីបង ទី២

រ៉ាស៊ីៈ បងពូស្រី ឬប្រុស?

ផន៖ ស្រី ។

ភ៉ាស៊ី៖ ស្រីប៉ុន្មានប្រុសប៉ុន្មាន?

ផន៖ ស្រី៣ ។

ភ៉ាស៊ី៖ ប្រុស៣?

ផន៖ បាទ!

ភ៉ាស៊ី៖ កាលជំនាន់ហ្នឹងចូលបដិវត្តន៍ប៉ុន្មាននាក់ដែរ?

ផន៖ កាលហ្នឹងចូលខ្ញុំនិងបងខ្ញុំហ្នឹង ។ ក្រៅពីហ្នឹងនៅតូចៗ ។

ភ៉ាស៊ី៖ ពូ និងបងពូហ្នឹងចូលថ្ងៃជាមួយគ្នាផ្សេងគ្នា?

ផន៖ ខ្ញុំទៅមុនបងខ្ញុំ ។

ភ៉ាស៊ី៖ អូ ពូទៅមុនទៀត?

ផន៖ ហ្នឹងហើយ ។

ភ៉ាស៊ី៖ ពូ ទៅឆ្នាំណាដែរ?

ផន៖ ខ្ញុំទៅចុងឆ្នាំ១៩៧២ហើយ ជិត៧៣ ខ្ញុំទៅ ។

ភ៉ាស៊ី៖ ចុងឆ្នាំ?

ផន៖ ចុងឆ្នាំ១៩៧២ នៅមួយខែពីរខែចូលឆ្នាំ១៩៧៣ ។

ភ៉ាស៊ី៖ ចុះបងពូចូលឆ្នាំណាដែរ?

ផន៖ ទេ បងមិនដឹងចូលឆ្នាំណាទេ ខ្ញុំទៅយូរដែរបានបងចូល ។ បងខ្ញុំឆ្នាំ១៩៧៣-៧៤អីហ្នឹង គាត់ទៅស្រែអំបិល ។

ភ៉ាស៊ី៖ ទៅធ្វើស្រែអំបិល?

ផន៖ បាទ!

ភ៉ាស៊ី៖ ចុះរាល់ថ្ងៃគាត់បានវិលត្រឡប់មកផ្ទះវិញដែរ?

ផន៖ គាត់ឥឡូវនៅអាមេរិក ។

ភ៉ាស៊ី៖ ពេលនៅហ្នឹង ពេលបែកឆ្នាំ១៩៧៩គាត់ទៅបណ្តោយ?

ផន៖ ហ្នឹង កាលវៀតណាមបុកចូលហ្នឹង គាត់ទៅរហូតទៅ ។

វ៉ាស៊ីៈ ពូ តាំងពីពូចូលបដិវត្តរហូតដល់បច្ចុប្បន្ន ខ្ញុំចង់ឲ្យពូរៀបរាប់ពីប្រវត្តិរបស់ពូ ពូចាំប៉ុន្មានពូរៀបរាប់ប៉ុណ្ណឹងទៅ?

ផនៈ ខ្ញុំរៀបរាប់តាំងពីខ្ញុំចូលមក?

វ៉ាស៊ីៈ បាទ!

ផនៈ ហ្នឹងរៀនរាប់តាំងពីការលំបាករបស់ខ្ញុំ?

វ៉ាស៊ីៈ បាទ សកម្មភាពរបស់ពូ ។

វណ្ណៈ អាចនិយាយកាលពីក្មេកពូរៀនបានត្រឹមប៉ុណ្ណាអីក៏បាន?

ផនៈ ក្មេងៗរៀនខ្សោយដែរហ្នឹង កាលហ្នឹង ខ្ញុំចូលតាំងពីឆ្នាំ១៩៧៣ តាំងពីចូលមក អើធម្មតាកាលហ្នឹងវាវេទនាតិចហើយ ។ យើងចូលទៅយើងធ្វើម៉េច ការចូលបំរើជាតិកាលហ្នឹងបើយើងមិនទៅក៏មិនកើតដូច្នេះអ្នកពេកកំលាំងដូចគ្នាត្រូវតែទៅ ទៅហើយហ្នឹងមុនដំបូងនៅឈ្លបទេ នៅឈ្លបឃុំដល់បានហើយ បានខ្ញុំនៅនិរសាស្រុកបានមួយឆ្នាំ បានហើយ ដល់ពេលនេះ គេធ្វើប្រវត្តិរូបស្រាប់យកបងវៃចោល ។ យកបងវៃចោលបងអិតនេះ ។ ដល់នេះគេធ្វើប្រវត្តិរូប ធ្វើប្រវត្តិរូបហើយចឹងទៅក៏គេដកខ្ញុំមកមួយរយៈខ្លះប្រហែលជា៣-៤ គេទុកចិត្តខ្ញុំដល់ហើយបានគេរើសខ្ញុំមួយសារទៀតយកទៅនៅភ្នំពេញ ។ ទៅនៅភ្នំពេញនៅជាមួយភ្ញៀវបរទេស ។ នៅក្រសួងកាបរទេស ។

វ៉ាស៊ីៈ ទៅនៅក្រសួងការបរទេស?

ផនៈ ហ្នឹងហើយ នៅដល់ពេលយួនបុកចូលបានខ្ញុំបែកចេញទៅទ័ព ។ វៃរហូត ។

វ៉ាស៊ីៈ ពេលយួនបុកចូលបានពូចេញក្រសួងការបរទេសទៅធ្វើទ័ព?

ផនៈ គេរៀបថ្មីទៀត ។ គេរៀនវរៈថ្មី ខ្ញុំចូលទ័ពភ្នំពេញ ខ្ញុំអត់មានបានវៃនឹងគេផង វៃដែរវាស្រួល មិនសូវពិបាកប៉ុន្មានដែរ ។ វេទនាច្រើនដែររឿងខ្ញុំ បងអាចដឹងខ្លះហើយ ។ ការរស់នៅក្រោមរបបរបស់គេបើយើងមិនអនុវត្តន៍តាមគេ ក៏គេធ្វើបាបដូច្នេះបញ្ហាហ្នឹងពិបាកបង អាចដឹងខ្លះហើយ ។

វ៉ាស៊ីៈ ពេលពូចូលធ្វើបដិវត្តន៍ពូស្ម័គ្រចិត្តចូល?

ផនៈ កាលហ្នឹងគេហៅដែរ មានពួកម៉ាកគេចូលមុនគេហៅតាមក្រោយ ។

វ៉ាស៊ីៈ ឈ្មោះអីអ្នកហៅពូ?

ផន៖ អានី ។

រ៉ាស៊ី៖ ស្រីឬប្រុស?

ផន៖ ប្រុស ។

រ៉ាស៊ី៖ គាត់ធ្វើអី?

ផន៖ កាលហ្នឹងវានៅជាមួយតាម៉ុត ។

រ៉ាស៊ី៖ តាម៉ុត?

ផន៖ គេហៅចូលទៅជាមួយគេទៅ ។ ប៉ុនដល់ទៅខ្ញុំនៅឃុំសិនទៅឈប់ឃុំសិន ។

រ៉ាស៊ី៖ តាម៉ុតហ្នឹងពីណាគេ?

ផន៖ តាម៉ុតហ្នឹងកាលហ្នឹង គាត់ធ្វើធំដែរ ។

រ៉ាស៊ី៖ ជាប់សាច់ឈាមជាមួយតាម៉ុកដែរអត់ទេ?

ផន៖ បែបជាប់ ការងាររបស់គេ ខ្ញុំមិនដឹងការងារផ្ទៃក្នុងរបស់គេថា គេបងប្អូនយ៉ាងម៉េចខ្ញុំអត់បានដឹង ។ ខ្ញុំរស់នៅជាមួយតាម៉ុតក៏បានរស់នៅជាមួយគាត់ដែរ ។

រ៉ាស៊ី៖ កាលពូចូល ចូលនៅណាដែរ?

ផន៖ ខ្ញុំចូលនៅឃុំគេហ្នឹងហ្នង ។

រ៉ាស៊ី៖ នៅឃុំ កាលហ្នឹងមិនឃុំដូងខ្ពស់ទេ?

ផន៖ មិនមែនទេ នៅភូមិដងក្តុល ។

រ៉ាស៊ី៖ កាលពូចូល ចូលប៉ុន្មាននាក់ម៉ាជំនាន់ពូ?

ផន៖ កាលចូលតែខ្ញុំមួយ ម៉ែឪនៅលើ ។ ខ្ញុំចូលម៉ែឪគ្មានដឹងទេ ។

រ៉ាស៊ី៖ ម៉ែឪអត់ដឹងទេ?

ផន៖ អត់ដឹងទេ ។

រ៉ាស៊ី៖ ចុះបើសិនជាគាត់ដឹង យ៉ាងម៉េច?

ផន៖ បើដឹងបែបគាត់ឃាត់ក៏ម៉េច ។

រ៉ាស៊ី៖ ចិត្តចង់ទៅហើយ?

ផន៖ ចង់ទៅហើយ ។ បើគេចេះតែហៅធ្វើម៉េចពេញកំលាំងពេញវ័យហើយ ។

រ៉ាស៊ី៖ កាលហ្នឹងពូអាយុប៉ុន្មាន?

ផនៈ	កាលហ្នឹងខ្ញុំអាយុ១៦ឆ្នាំ ឬ១៧-១៨ ខ្ទង់ប៉ុណ្ណឹង ។

រ៉ាស៊ីៈ	ពូ នឹកឃើញម៉េចបានចង់ចូលធ្វើបដិវត្តន៍?

ផនៈ	ទេ កាលហ្នឹងក្មេីតក្មេីនគេហៅទៅ បើមិនទៅគេហៅជៀសមិរួច ជៀសមិនផុត ។

រ៉ាស៊ីៈ	ដែលពូសួរឃោសនារបស់អ្នកណាម្នាក់ឬសកម្មជនណាម្នាក់នៅក្នុងភូមិឃុំ គេឃោសនាថាម៉េចបានជយើងចេះចង់ចូលធ្វើបដិវត្តន៍?

ផនៈ	កាលហ្នឹងដូចគ្មានទេ គ្មានជំហរទេ គ្មានពីណាឃោសនាអ្វីឲ្យថាបំផុសឲ្យចូល នេះចិត្តមានពួកម៉ាកហៅចេះទៅតាមគ្នាទៅ ។ ម៉ាឆាវកាលហ្នឹង ប៉ុនបើមិនទៅមានមុខការងារធ្វើនៅក្នុងភូមិដល់នេះចេញឲ្យផុត ។

រ៉ាស៊ីៈ	កាលហ្នឹងប្រធានឃុំអន្លង់ខ្ទរឈ្មោះអី កាលពូចូលធ្វើបដិវត្តន៍?

ផនៈ	ពូ ទូច អូនៅកំពតមិនដឹងពីណាទេ ។

រ៉ាស៊ីៈ	ដំនាន់ឆ្នាំ១៩៧២កាលពូចូលធ្វើបដិវត្ត?

ផនៈ	មិនដឹង អ្នកណាគេ ។ បងអាចដឹងទេ ខ្ញុំចេញផុតទៅ ។

រ៉ាស៊ីៈ	កាលហ្នឹងស្រុកទ្រាំងគេហៅស្រុកលេខប៉ុន្មាន?

ផនៈ	ស្រុកទ្រាំង១០៧ ។

រ៉ាស៊ីៈ	ចុះកន្លែងចូលផ្សារ?

ផនៈ	នេះអត់ទាន់មានស្រុកទេ ។

រ៉ាស៊ីៈ	អូ អត់ទាន់មានស្រុកទេ ។

ផនៈ	កោះអណ្តែតគេហៅ១០៨ ។

រ៉ាស៊ីៈ	ត្រាំកក់១០៥ មកទ្រាំង១០៧ ហីកោះអណ្តែត១០៨ ។ ចឹង ១០៦អាចស្រុកសំរោង

ផនៈ	បាទ!

រ៉ាស៊ីៈ	ពូកាលហ្នឹងធ្វើការមានដឹងទេ ហេតុអីបានជាគេចូលដាក់ឈ្មោះឈ្មោះជាលេខវិញ?

ផនៈ	ទេ មិនដឹងទេ ។ ខ្ញុំមិនសូវដឹងទេ រៀនមិនដល់ហ្នឹងយ៉ាប់ចឹង ។ វាពិបាកចឹង ។

រ៉ាស៊ីៈ	ពូ ពេលពូចូលពីណាគេអ្នកទទួលស្គាល់ពូ កាលចូលធ្វើបដិវត្ត អ្នកចុះឈ្មោះពូ អ្នកទទួលស្គាល់ពូថាបានចូលធ្វើបដិវត្ត?

ផនៈ	កាលហ្នឹងបងសៀង បងសានៗ បងសាននៅ១០៥ៗ ហីប្រធានឃុំនេះមានតែតាផនៗ តាផនគាត់នៅៗ

រ៉ាស៊ីៈ	សៀង និង សាន នាទីគាត់ជាអីដែរ?

ផនៈ	សាន ជាគណៈស្រុកៗ

រ៉ាស៊ីៈ	ទាំងពីនាក់ហ្នឹងគណៈស្រុក១០៧?

ផនៈ	១០៧ៗ

រ៉ាស៊ីៈ	ពេលដែលពូចូលហ្នឹងមេភូមិ មេឃុំអីគេដឹងទេ គេមានដឹងថាពូចូលធ្វើបដិវត្តន៍?

ផនៈ	អត់ដឹងទេៗ

រ៉ាស៊ីៈ	ពូថា ពូចូលឃុំ ម៉េចមេឃុំអត់ដឹង?

ផនៈ	អត់ដឹងយើងចូលទៅហ្នង យើងចូលទៅគ្រាន់បានឈ្មោះពីរបីហ្នឹងគេអត់ដឹងៗ

រ៉ាស៊ីៈ	ប្រមូលចូលព្រៃហ្នង?

ផនៈ	ហ្នឹងហើយ ទៅធ្វើទ័ពហ្នងៗ

រ៉ាស៊ីៈ	ពេលដំបូងពូចូលទៅធ្វើនៅណា?

ផនៈ	ពីមុននៅហ្នឹងដល់ហើយបានគេយកទៅខាងកើតតាកែវធ្វើសន្ត្រាមនៅហ្នឹងៗ នៅបាន៣-៥ ខាងកើតតាកែវៗ

រ៉ាស៊ីៈ	ចឹង កាលដំបូងពូធ្វើឈ្លបនៅឃុំអន្គខ្នុរ?

ផនៈ	បាទ!

រ៉ាស៊ីៈ	បាន៥-៦ខែបានទៅ?

ផនៈ	អត់ទេ បាន៤-៥គេរើសខ្ញុំនៅនៅធ្វើនិរសាៗ

រ៉ាស៊ីៈ	និរសាស្រុក?

ផនៈ	បាទ និរសាស្រុក របសតាសៀង នៅជាមួយទ័ពផ្ទាល់ៗ

រ៉ាស៊ីៈ	និរសាឲ្យតាសៀងហ្នង?

ផនៈ	ហ្នឹងហើយៗ

រ៉ាស៊ីៈ	ពូនៅឃុំការងារអីខ្លះឈ្លបឃុំ ការងោរម៉េច?

ផនៈ ទេ កាលខ្ញុំនៅហ្នឹងមានធ្វើអីគ្រាន់តែកិនអង្ករស៊ី ។ ឈ្លបឃុំគេនៅមុខហ្នឹង ហើយយើង អ្នកសេដ្ឋកិច្ចក្រោយ គេអ្នកកាន់កាប់ក្រោយមានធ្វើអី ។

វណ្ណៈ ចុះការផារនិរសារធ្វើអីខ្លះ?

ផនៈ គេគ្រាន់តែប្រើយើងរត់សំបុត្រនាយអាយហ្នឹង ។ មេទៅណា គេប្រើយើង ដូចថាទៅតាកែវទៅកោះអណ្តែតទៅកន្លែងអាគារមុខៗ ។

រ៉ាស៊ីៈ កាលពូទៅតាកែវ ពូរត់និរសាទៅខាងណា?

ផនៈ ខ្ញុំអត់នៅតាកែវទេ ខ្ញុំនៅកន្លែងមន្ទីរស្រុកហ្នឹង ។

វណ្ណៈ នៅស្រុកសិន?

ផនៈ ហ្នឹងហើយ ។

វណ្ណៈ នៅស្រុកហ្នឹងរត់និរសាទៅខាង?

ផនៈ អាហ្នឹងស្រេចគេប្រើទៅហ្នឹងហើយ យើងរត់សំបុត្រឲ្យគេយើងនិរសា ។

វណ្ណៈ កាលហ្នឹងពូទៅមកដើម្បីយកសំបុត្រទៅមកហ្នឹង កាលហ្នឹងពូជិះអីដែរ?

ផនៈ ដើរគ្មានជិះទេ ជួនណាចឹងម៉ូតូគេទំនេរជិះម្តងទៅបើទៅផ្លូវឆ្ងាយ ជិះសេះចឹងទៅ ។

រ៉ាស៊ីៈ មានសេះជិះដែរ?

ផនៈ មាន ។

វណ្ណៈ បន្តទៀតពូទៅណាទៀត?

ផនៈ ដកពីនិរសាខ្ញុំទៅនៅភ្នំពេញវិញ ។

វណ្ណៈ ចុះពូថាទៅនៅតាកែវ?

ផនៈ អត់មាននៅតាកែវទេ ទៅភ្នំពេញហ្នឹង

រាសីៈ ពូទៅដល់ដំបូងពូទៅធ្វើអីដែរ?

វណ្ណៈ ទៅភ្នំពេញ ពូទៅដល់ដំបូងពូទៅធ្វើអីដែរ?

ផនៈ ទៅមុនដំបូងទៅដល់.....ទៅរៀនហ្នឹងទៅបាមកន្លះខែ ។

វណ្ណៈ ទៅរៀន រៀនអីគេ?

ផនៈ រៀនច្បាប់ ។

វណ្ណៈ គេនិយាយអំពីខ្លះ?

ផនៈ គេនិយាយពីយើងទៅនៅក្រសួងការបរទេសវិន័យច្បាប់ នៃនយោបាយហ្នឹង ។

វណ្ណៈ ពូទៅរៀនហ្នឹងពូស្គាល់ពីណាខ្លះទេ អ្នកធំនៅហ្នឹង?

ផនៈ មិនសូវស្គាល់ទេ ។ ប្រធានមន្ទីរមន្ទីរ បងហុន បងនួស? បងនួសហ្នឹងគាត់មេប្រធាន

វណ្ណៈ ពូធ្វើការនៅក្រសួងការបរទេសហ្នឹង ពូមានស្គាល់ធំខ្មែរ ឬជនជាតិបរទេសអីមកទេ?

ផនៈ ស្គាល់ភ្លេចអស់ ។ បងហុនស្គាល់ដែរ ។

វណ្ណៈ ពូ មានឃើញបរទេសមកទេ?

ផនៈ មកដែរ ។

វណ្ណៈ តាមពូដឹងតើជនជាតិបរទេសហ្នឹងជនជាតណាមួយ ជនជាតិអី?

ផនៈ ចិន កូរ៉េ វៀតណាមយើងហ្នឹង ប៉ុនដល់ពេលឃួនបុកចូលរយៈពេល៦-៧ថ្ងៃដកវៀតណាមចេញដកថ្ងៃ៦ ។

វណ្ណៈ មានវៀតណាមដែរ?

ផនៈ មាន តែដកវៀតណាមចេញវិញហើយនៅពេអុកឡុកខ្លាំង ។

វណ្ណៈ នៅឆ្នាំណា?

ផនៈ ដកវៀតណាមនៅឆ្នាំ១៩៧៦ ។

វណ្ណៈ ឆ្នាំ១៩៧៦ នៅក្រសួងការបរគេសមានវៀតណាមដែរ?

ផនៈ មាន គេដកទូត កាលខ្មែរយើងកាលហ្នឹង ។

វណ្ណៈ មានទូតអីខ្លះបើតាមពូដឹង?

ផនៈ គុយ បា, វៀតណាម, ចិន, កូរ៉េ និងមួយទៀតខ្មៅ ។ ទាំងអស់៧-៨ទូតហ្នឹង ។ ដូចកាលហ្នឹងយើងមិនបានដើរគ្រប់កន្លែងស្គាល់ដែរ តែមិនបានស្គាល់អស់ ។

រ៉ាស៊ីៈ កាលពូធ្វើនិរសារនៅស្រុកហ្នឹងពូធ្វើរយៈពេលប៉ុន្មានឆ្នាំដែរ?

ផនៈ និរសាខ្ញុំធ្វើបាន៦-៧ខែ ថាប៉ុណ្ណឹងចុះ ។

រ៉ាស៊ីៈ ពីឆ្នាំណាទៅ?

ផនៈ ខ្ញុំធ្វើនិរសាចុងឆ្នាំ១៩៧៤ដិត៧៥ ។

រ៉ាស៊ីៈ ចឹង គេដកពូទៅភ្នំពេញហ្នឹងនៅពេលដែលវៃចូលទីក្រុងហើយ?

ផនៈ ហ្នឹងវៃបែកភ្នំពេញហើយអស់ ។

រ៉ាស៊ីៈ ពេលវៀតណាមបែកភ្នំពេញហើយភ្លាម ពូគេទាយយកទៅភ្នំពេញ?

ផនៈ វៀតណាមបែកភ្នំពេញហើយភ្លាមខ្ទង់រយៈពេល៣-៤ខែ ។ ៣ខែបានគេរើសពីស្រុកទៅ ទៅនៅហ្នឹង ។

រ៉ាស៊ីៈ ៣ខែក្រោយបានពូទៅភ្នំពេញ?

ផនៈ ហ្នឹងហើយ ។

រ៉ាស៊ីៈ កាលហ្នឹងពីណាគេអ្នកខទ្ទេសនាមឲ្យពូឡើងទៅធ្វើការភ្នំពេញ?

ផនៈ បងសាន បងសៀង ស្រុកហ្នឹង ។

រ៉ាស៊ីៈ ចុះពីណាឡើងមកធ្វើនិរសាជំនួស?

ផនៈ ទេមិនដឹងពីណាក្រោយខ្ញុំចេញផុតហើយ មិនដឹងដែរ ។

រ៉ាស៊ីៈ ក្នុងរយៈពេលចូលបដិវត្តន៍ពចុងឆ្នាំ១៩៧២រហូតដល់ដើមឆ្នាំ១៩៧៥ ពូមានខស្សាហ៍ចេញចូលមកលេងផ្ទះទេ?

ផនៈ មកដែរប៉ុនមកតែម្តងទេ ។ កាលហ្នឹងខ្ញុំមិនទាន់បាន......មកជាមួយកូរ៉េចិនហ្នឹង ។

រ៉ាស៊ីៈ ហ្នឹងបន្ទាប់ពីឆ្នាំ១៩៧៥មក ពូទៅធ្វើនៅភ្នំពេញ គាសៀង គាសានហ្នឹងខទ្ទេសនាមឲ្យពូទៅ?

ផនៈ ហ្នឹងហើយ ។

រ៉ាស៊ីៈ គ្រាន់គាត់ខទ្ទេសនាមទៅ ខាងនោះគេទទួលពូយកទៅ?

ផនៈ គេទទួលនៅសាលារៀនហ្នឹងអត់មានទាន់ស្គាល់ឈ្មោះគេប្រធានទេ ព្រោះយើងទើបទៅមិនទាន់ស្គាល់ ។

រ៉ាស៊ីៈ ពូទៅដល់ភ្លាមគេឲ្យពូធ្វើអីទៅដល់ក្រសួង?

ផនៈ ទៅដល់រៀន រៀនកន្លះខែបានគេចែកការងារមកយើង ឲ្យយើងនៅតាមក្រសួង ។

រ៉ាស៊ីៈ រៀនកន្លះខែ រៀនហ្នឹងពីណាអ្នកបង្រៀន?

ផនៈ រៀនហ្នឹង ដូចបងហុងកាលហ្នឹង រៀនហើយបានចែកទៅតាមក្រសួងការបរទេសកាលហ្នឹងនៅតាមមន្ទីរ ។

រ៉ាស៊ីៈ ហុង ហ្នឹងត្រកូលអីហុង?

ផនៈ មិនដឹងទេ ភ្លេចឈ្មោះជីតាហើយ ។

វ៉ាស៊ីៈ  រូបរាងគាត់យ៉ាងម៉េចដែរ?

ផនៈ  គាត់ស ។

វ៉ាស៊ីៈ  ស រាងខ្ពស់?

ផនៈ  ស រាងទាប រាងដូចសុខអានអីចឹង ។ ស្រដៀងចិន ។

វ៉ាស៊ីៈ  កាត់ចិនចឹង?

ផនៈ  ហ្នឹងហើយស្រដៀងគ្នា ។

វ៉ាស៊ីៈ  គាត់មកពីណាស្រុកកំណើតគាត់?

ផនៈ  ស្រុកកំណើតមកពី.........មកពីក្រចេះ ។

វ៉ាស៊ីៈ  ពូដឹងអត់ច្បាស់ដែរ?

ផនៈ  រឿងមិនច្បាស់ដែរ ចុះយើងកាលហ្នឹងនៅមិនបានសួរគេអារឿងហ្នឹង ។ កាលហ្នឹងនៅភ្នំពេញស្ងាត់ហ្មង ។

វ៉ាស៊ីៈ  កាលហ្នឹងគាត់មាននាទីអីដែរនៅក្នុងក្រសួង?

ផនៈ  គាត់ប្រធានក្រសួងការបរទេសប្រធានមន្ទីរ ។

វ៉ាស៊ីៈ  ប្រធានមន្ទីរ?

ផនៈ  .......ភ្ញៀវដែលមកហ្នឹង ធ្វើមេគាត់អ្នកចាត់ចែង ។ ទៅទស្សនៈកិច្ចទៅនរគវត្តទៅណាព្រះវិហារ បាត់ដំបងអី មណ្ឌលគិរីនៅលើគាត់អ្នកចាត់ចែង ។

វ៉ាស៊ីៈ  លើគាហុងហ្នឹងទាំងអស់?

ផនៈ  ហ្នឹងហើយ ។

វណ្ណៈ  ចុះពូមានតួនាទីដើរតាមភ្ញៀវដែរ?

ផនៈ  ដើរដែរ ។

វណ្ណៈ  ចុះពូចេះភាសាដែរចឹង?

ផនៈ  អត់ទេ ។

វណ្ណៈ  ចឹង ពូគ្រាន់ជាអ្នកការពារ?

ផនៈ  ហ្នឹងហើយ ដើរជាមួយនឹងគេ ។

វណ្ណៈ  ចុះអ្នកចេះភាសាអ្នកបកប្រែមានដែរ?

ផន:	មានដែរ ។

វណ្ណះ:	ខ្មែរ?

ផន:	ខ្មែរ ។

វណ្ណះ:	ពូ ស្គាល់ទេអ្នកបកប្រែ?

ផន:	តាធឿន ។

វណ្ណះ:	ធឿន?

ផន:	មិនស្រួលផាប់បាត់ហើយ កាលវៀតណាមបាញ់ចូល បែបផាប់ហើយស្វាត់ឈឺផមិន ដែលពុសំឡេងសោះ ។

វណ្ណះ:	ចុះពូមានច្បាស់ក្នុងខ្លួនទេថា ថាទូតមានវៀតណាមមែនមានច្បាស់ទេ?

ផន:	មាន កាលហ្នឹងគេដកទូតទៅវិញ ។

វណ្ណះ:	ដកឆ្នាំណា?

ផន:	ដកឆ្នាំ១៩៧៦ ខែប៉ុន្មានទេ ។ ដកឆ្នាំ១៩៧៦ ។

វណ្ណះ:	ចុះទូតទៃទៀតមានដកទេ?

ផន:	អត់ទេ ។

វណ្ណះ:	ដកតែទូតវៀតណាមមួយចេញទេ?

ផន:	ដល់ពេលចុះចូលខ្លាំងចេញលទ្ធផលទីផ។អ្នកណាទៅណាទៅណី អត់ដឹងដែរ ។ ខ្ញុំកាល ពួកភ្នំពេញទៅទីផហ្នឹងខ្ញុំនៅភ្នំពេញដែរ ។

វណ្ណះ:	ពូអត់រត់ទេ?

ផន:	ដល់ពេលខ្ញុំផមែនទែនបានរត់ ម៉ោង៦ ផេះភ្នំពេញ ផេះឃ្លាំងសាំងនៅផ្សារឃ្លាំងរំសេវ ផេះតែពីរឃ្លាំងហ្នឹងទេ ។

វណ្ណះ:	ចុះពូរដ្ឋមន្ត្រីក្រសួងការបរទេសពូស្គាល់ទេ?

ផន:	ទេ កាលហ្នឹងមានអាណាទេ គ្នាច្រើនចេះមិនដឹងអាណាអាណីទេ មានតែបងហុងទេ ខ្ញុំដឹង ច្បាស់ ។

ភាស៊ី:	ពូនៅជាប់ជាមួយហុងហ្នឹងហ្មង?

ផន:	ហ្នឹងហើយ ។

រ៉ាស៊ីៈ នៅក្រសួងការបរទេសបន្ទាប់ពីរៀនចប់ហ្នឹងពូមានមុខងារអីមួយច្បាស់លាស់ទេ?

ផនៈ មានតើ ដល់ពេលខ្ញុំខុស ។

រ៉ាស៊ីៈ ខុសម៉េច?

ផនៈ ខុសសីលធម៌គេទំលាក់ខ្ញុំមកវែកអាម៌នៅតាខ្មៅ ។ ខ្ញុំចេញបាវំហើយ ។

វណ្ណៈ ពូខុសសីលធម៌?

រ៉ាស៊ីៈ ពូធ្វើការបានប៉ុន្មានឆ្នាំបានពូខុសសីលធម៌?

ផនៈ ខ្ញុំធ្វើបានយូរដែរ ខ្ញុំចូលសម្ព័ន្ធយុវកក យុវជន នៅកន្លែងណា ។

រ៉ាស៊ីៈ មុនពូខុសសីលធម៌ហ្នឹងកាលហ្នឹងពូមានឋានៈអី?

ផនៈ ទេ មិនទាន់ដែរខ្ញុំចូលសម្ព័ន្ធយុវកកបក្ខជន ថែកការងារយើងមិនទាន់ចាត់ចែងយើងហ្នឹង គេអាចទុកចិត្តយើង.....តាមគេខ្វះហើយជំនាន់ហ្នឹងព្រោះចំណេះយើងខ្សោយស្តាប់បានដឹងទេ ។

វណ្ណៈ ចុះខុសសីលធម៌ជាមួយ ចុះនារីដែលពូស្រឡាញ់ហ្នឹងម៉េច គេចាប់?

ផនៈ ការជាមួយខ្ញុំហើយ ដល់ពេលយួនបុកមកបាត់ទៅ ។

រ៉ាស៊ីៈ បានបែកគ្នាទៅ?

ផនៈ ហ្នឹងហើយ ។

រ៉ាស៊ីៈ កាលហ្នឹងគាត់ឈ្មោះអីដែរ?

ផនៈ ឈ្មោះធី ។

វណ្ណៈ ពូនិយាយម៉ិញថា បានការជាមួយគាត់?

ផនៈ ហ្នឹងហើយ ខ្ញុំការហើយ ការនៅសង្គម ប៉ុល ពត ហ្នឹង ។

វណ្ណៈ ការម៉េចទៅជាខុសសីលធម៌បាន?

ផនៈ មុនយើងយក ដែលយើងទាក់ទងហ្នឹង ។

វណ្ណៈ អូ យើងខុសសីលធម៌ហើយ គេការឲ្យយើងតែម្តង ។

ផនៈ ហ្នឹងហើយ ។

រ៉ាស៊ីៈ ចុះអ្នកណាអ្នកដឹងថា ពូខុសសីលធម៌?

ផនៈ គេអ្នកធ្វើការជាមួយគ្នា ធ្វើការជាមួយគ្នអាដឹងចិត្តថាបងឯងពេលស្ងាត់គេអាចដឹង ។

រ៉ាស៊ីៈ រយៈពេលប៉ុន្មានបន្ទាប់ពីខូចសីលធម៌បានគេរៀបការឲ្យយើង?

ផនៈ តែមួយខែ ។

រ៉ាស៊ីៈ ចាប់តាំងពីហ្នឹងមកគេដកពូលែងឲ្យធ្វើការនៅហ្នឹង?

ផនៈ លែងរហូត មកវែកអាចម៍នៅតាខ្មៅ ។ ៨-៩ខែ ។

រ៉ាស៊ីៈ នៅណា?

ផនៈ នៅក្រូចរខ្មៅ ។

រ៉ាស៊ីៈ អូនៅក្រូចតាខ្មៅ គេយកមកដាក់ហ្នឹង?

ផនៈ យកមកដាក់ហ្នឹង ។

រ៉ាស៊ីៈ ការហើយបានគេយកមកដាក់ហ្នឹង?

ផនៈ ហ្នឹងហើយ ។

រ៉ាស៊ីៈ ធ្វើអីនៅហ្នឹង?

ផនៈ ដាំស្ពៃ ។

រ៉ាស៊ីៈ អូ ចឹងសុទ្ធអ្នកនេះហើយនៅហ្នឹង អ្នកមានទោស?

ផនៈ អ្នកមានទោស ។ ដាំស្ពៃហ្នឹង ។ ក្រៅពីខ្ញុំគេបាញ់ចោលដែរ ។ ប៉ុនធ្វើមិនចេញដែរ ធ្វើខ្ញុំម៉េចចេញ បើខ្ញុំនេះប្រូចបាត់ទៅស្វាយរៀងឥឡូវហ្នឹង ខ្ញុំទៅឥឡូវហ្នឹង ។

រ៉ាស៊ីៈ នៅឆ្នាំណាដែរពូ?

ផនៈ នៅឆ្នាំ១៩៧៥ ជិតចូល៧៦ហើយ ។

រ៉ាស៊ីៈ ពូទៅរៀនហើយ ធ្វើការបានប៉ុន្មានខែបានពូខូចសីលធម៌ហ្នឹង?

ផនៈ បានខ្ទង់៣-៤ខែ ។

រ៉ាស៊ីៈ ចុះទៅដាំស្ពៃ?

ផនៈ បាន៨ខែ ។

រ៉ាស៊ីៈ ដាំស្ពៃបាន៨ខែ?

ផនៈ ហ្នឹងហើយ រយៈពេលក្នុងហ្នឹងយួនបុកចូលហើយ ។ វៀតណាមបុកចូលឆ្នាំ១៩៧៦ចឹង?

រ៉ាស៊ីៈ វៀតណាមចូលឆ្នាំ១៩៧៧ ។

ផនៈ អើ ឆ្នាំ១៩៧៦-៧៧ហ្នឹង ។

រ៉ាស៊ីៈ បានឆ្នាំ១៩៧៩មកមួយសារទៀតបែក ។

ផនៈ ហ្នឹងហើយ យួនបុកមកដល់ភ្នំ ដុំវិញ ។

រ៉ាស៊ីៈ ចុះពូចេញពីដាំស្ពែហ្នឹងទៅណាទៀត?

ផនៈ ចេញពីដាំស្ពែដល់យួនបុកចូលបាននែកទៅណោះ ។

រ៉ាស៊ីៈ បែកទៅនៅទ័ពវិញ?

ផនៈ ទៅរហូតនេះនោះ ។

រ៉ាស៊ីៈ ពូទៅទ័ពហ្នឹងនៅកងពលណាដែរ?

ផនៈ កងពល១២ ។

រ៉ាស៊ីៈ វរសេនធំប៉ុន្មាន វរសេនាតូចប៉ុន្មាន?

ផនៈ វរសេនាតូចលេខ៣ ។

រ៉ាស៊ីៈ ចុះធំ?

ផនៈ ធំ១២ តាវវៃស្គាល់ទេ?

រ៉ាស៊ីៈ នៅក្នុងកងពលហ្នឹងវាមានវរសេនាធំ វរសេនាតូច និងអនុសេនាធំអនុសេនាតូច?

ផនៈ មាន៣ ។

រ៉ាស៊ីៈ ចឹងពូនៅវរសេនាធំលេខ៣?

ផនៈ ហានឹងហើយលេខ៣ ។

វណ្ណៈ ចុះប្រធានកងពលឈ្មោះអី?

ផនៈ តាវវៃ ។

វណ្ណៈ ពូមានដឹងថាគាត់ សព្វថ្ងៃនៅរស់ដែរ?

ផនៈ ទេបង បេកយូរមិនដឹងម៉េច ជិត២០ឆ្នាំហើយមិនដឹងម៉េច ។ គ្នាឯងឥឡូវហ្នឹងមិនដែលព្រុ ឈ្មោះសូម្បីតែពួកម៉ាកមិនដែលព្រុឈ្មោះផងមិនដឹងម៉េច ។ វាចឹង មិនអាចកំណត់មិនឃើញ

វណ្ណៈ ចុះតាវវៃហ្នឹងចរិកលក្ខណៈគាត់កាចសាហាវទេ?

ផនៈ ទេ ស្លូតដែរ ។ មានកាចអីចំពោះពួកខ្ញុំ គេអ្នកក្រោមមិនដឹងម៉េច បើពួកខ្ញុំដឹងចិត្ត ។

វណ្ណៈ ពូខ្លាំងដែរ ។

ផនៈ ដែលហ៊ានដាមួយខ្ញុំ ។

រ៉ាស៊ីៈ ពូនៅក្រសួងការបរទេសហ្នឹងបើតាមពូធ្វើការប៉ុន្មានខែពូមានដឹងទេថា គេចែកចេញជាប៉ុន្មានមន្ទីរដែរ ក្នុងក្រសួងមានមន្ទីរអីខ្លះ?

ផនៈ មន្ទីរច្រើនដែរ ខ្ញុំមិនទាន់បានដើរគ្រប់ផង ខ្ញុំនៅមន្ទីរប១ ។

រ៉ាស៊ីៈ ពូនៅមន្ទីរប១?

ផនៈ ហ្នឹងហើយ ។

រ៉ាស៊ីៈ ប ហ្នឹងបានន័យថាម៉េច?

ផនៈ ប បានន័យថាយើងនៅជាមួយក្រសួងការបរទេសដាក់ចឹងហើយ តាមមើលពួកហ្នឹងរកកំណត់ មិនឃើញស្របក់ហ្នឹង ។

រ៉ាស៊ីៈ ប១ ចុះប២ខាងអី ប១ ខាងអី ប២ ខាងអី?

ផនៈ អាខ្លះគេដាក់ប១ ប៣ អាខ្លះគេនៅបោសសំអាតក្រុងអាខ្លះគេនៅបោសសំអាតតាមអាខ្លះនៅបោសសំអាតតាមផ្ទះ ។ ច្រើនកន្លែងណាស់ ។

រ៉ាស៊ីៈ ចុះប១ ហ្នឹងខាងអី?

ផនៈ នៅក្រសួងការបរទេសគេដាក់ចឹងហ្មង ។

រ៉ាស៊ីៈ នៅក្រសួងការបរទេសគេដាក់ប១?

ផនៈ ហ្នឹងហើយ ។ ខ្ញុំនៅជាមួយគេទេ គ្រាន់នេះ អើគេមានប្រជុំជាមួយអ្នកធំៗយើងទៅបំរើគេ

រ៉ាស៊ីៈ បំរើរបៀបយ៉ាងម៉េច?

ផនៈ យើងបំរើរបៀបបាយទឹកគេ ។

រ៉ាស៊ីៈ អូធើបាយធ្វើទឹកឲ្យគេ?

ផនៈ ហ្នឹងហើយ ។

វណ្ណៈ រៀបចំកម្មវិធីផ្សេង?

ផនៈ ហ្នឹងហើយ ។

រ៉ាស៊ីៈ ពូមានដែលឃើញអ្នកធំៗមកប្រជុំប៉ុន្មានដងក្នុងរយៈពេលដែលពូធ្វើការនៅក្នុងហ្នឹង?

ផនៈ គេប្រជុំច្រើនដងណាស់ ។

រ៉ាស៊ីៈ ច្រើនដងរាប់មិនឈ្នះទេ ឆាកប្រជុំៗ?

ផនៈ ហ្នឹងហើយឆាកប្រជុំៗ ។

រ៉ាស៊ីៈ  អ្នកណាខ្លះមកប្រជុំហ្នឹង?

ផនៈ  អ្នកគេធំៗពិបាកសន្និដ្ឋានណាស់?

វណ្ណៈ  ចុះពូមានស្គាល់ ប៉ុល ពត អៀង សារីទេ កាលសម័យហ្នឹង?

ផនៈ  ស្គាល់បើចូលប្រជុំម្ដងៗ ។

វណ្ណៈ  ពូ ស្គាល់គាត់ច្បាស់ទេ?

ផនៈ  ច្បាស់កាលហ្នឹង ឥឡូវមិនដែលស្គាល់ទេ ។

វណ្ណៈ  ប៉ុន្តែខ្ញុំចង់សួរថា កាលហ្នឹងពូស្គាល់?

ផនៈ  ស្គាល់គេចូលប្រជុំម្ដងៗស្គាល់ដែរ ។

វណ្ណៈ  ពីណាខ្លះពូរាប់មើល អាចអ្នកធំៗហ្នឹង?

ផនៈ  តាម៉ុក អៀងសារី, តាអីម្នាក់ទៀត, ខៀវ សំផន, គ្នាច្រើនណាស់អ្នកធំៗ ។

វណ្ណៈ  ចុះ នួន ជា អីម៉េចដែរ?

ផនៈ  អើ នួន ជាអីហ្នឹង ។ និយាយរួម ហ៊ុន សែន អីហ្នឹង ។

រ៉ាស៊ីៈ  ប៉ុល ពត អីឃើញទេ?

ផនៈ  ឃើញទាំងអស់ តាយើងអីហ្នឹង ។

រ៉ាស៊ីៈ  ឃើញតាយើងដែរ?

ផនៈ  ហ្នឹងហើយ ។

រ៉ាស៊ីៈ  ពូឃើញនៅឆ្នាំណាតាយើង?

ផនៈ  ទេ ខ្ញុំភ្លេចហើយ តាំងពីឆ្នាំ១៩៧៥ ។ តាំងពី៧៤ទៅ ។

រ៉ាស៊ីៈ  សម្ដេចសីហនុហ្នឹង?

ផនៈ  តាំងពីឆ្នាំ១៩៧៤ទៅ ។

វណ្ណៈ  សម្ដេចតា ចូលរួមប្រជុំដែរ?

ផនៈ  ហ្នឹងហើយ ។ តា ហ៊ុន សែន យើង ។

រ៉ាស៊ីៈ  អូ ហ៊ុន សែនយើង មិនមែនសម្ដេចតា សីហនុទេ?

ផនៈ  មិនមែនទេ ។ តា សីហនុ ក៏ខ្ញុំឃើញដែរនៅសង្គម ប៉ុល ពត នៅភ្នំពេញ ។

រ៉ាស៊ីៈ  តាសែនចូលប្រជុំដែល ចូលប្រជុំ?

ផន:	តាហ្នឹងចូលយូរដែរហើយ តាំងពីមុនគេនោះ ។

ពាំស៊ីៈ	មុនឆ្នាំ១៩៧៤ទៀត?

ផន:	ហ្នឹងហើយ ។

ពាំស៊ីៈ	ពូឃើញនៅណា?

ផន:	សម័យគាត់តស៊ូហ្នឹង ។

ពាំស៊ីៈ	ពូឃើញនៅណាដែរគាត់ប្រជុំហ្នឹង?

ផន:	កាលគាត់ប្រជុំនៅព្រៃមិនដឹងនៅស្អីទេ គ្នាគាត់ប៉ុន្មាននាក់ទេ ។ ខ្ញុំស្គាល់អ្នកធំប៉ុន្មាននាក់ដែរ ប៉ុនឥឡូវខ្ញុំភ្លេចអស់ហើយ នៅក្មេងកាលហ្នឹង ។

ពាំស៊ីៈ	តាសែន កាលហ្នឹងគាត់អាយុប៉ុន្មានដែរកាលគាត់ប្រជុំ?

ផន:	តាហ្នឹងកាលហ្នឹងអាយុច្រើនណាស់ ២០ ជាង ។ បែប២០ជាង ៣០ហើយ កាលហ្នឹងនៅក្មេង ។ ខ្ញុំ បែកម៉ែអាយុ១៦-១៧ឆ្នាំ ។ ហី គាត់ខ្ទង់អាយុ២៥-៣០ឆ្នាំ ។

ពាំស៊ីៈ	ពូ ឃើញហ្នឹងថានៅជិតដាច់១៩៧៨-៧៩ទេ?

ផន:	ហ្នឹងប៉ុនហ្នឹង ។

ពាំស៊ីៈ	មិនមេនក្នុងកំឡុងឆ្នាំ១៩៧៥-៧៦ទេ?

ផន:	មិនមែនទេ ។

ពាំស៊ីៈ	ចឹង ពូមានប្រសាសន៍ថាធ្លាប់ឃើញតាម៉ុក អៀង សារី, ខៀវ សំផន, នួន ជា, ប៉ុល ពត ចូលប្រជុំនៅក្រសួងការបរទេស?

ផន:	ចូលប្រជុំ ។

ពាំស៊ីៈ	នៅក្នុកំឡុងពេលដែលពូធ្វើការឆ្នាំ ១៩៧៥ហ្នឹង?

ផន:	ហ្នឹងហើយ ។ ឃើញគេ យើងអ្នកបំរើគេហ្នឹង ។

ពាំស៊ីៈ	គេមានអង្គរក្សអីគេទៅ ការពារដែរ?

ផន:	មានដែរ ។

ពាំស៊ីៈ	ពេលគេទៅប្រជុំហ្នឹង ពូមានបានទៅបំរើទឹកតែអីទេ?

ផន:	អត់ទេ លើនារី ខ្ញុំនៅក្រៅ ។

ពាំស៊ីៈ	គេប្រជុំហ្នឹងគេនិយាយពីអីខ្លះ?

ផន៖    ទេ គេប្រជុំវៃគេស្តាប់មិនឮទេ ។

វណ្ណ៖  ពូគ្រាន់ជាអ្នកការពារខាងក្រៅហ្នឹង?

ផន៖    ហ្នឹងហើយ អ្នកនៅក្រៅ ។ នៅមើលគេខាងក្រៅ គេអ្នកបំរើផ្ទាល់ ។

**Side B**

ផន៖    មកពីក្រចេះ ។

វ៉ាស៊ី៖  អូ នារីទាំងអស់ហ្នឹងមកពីព្រហវិហារ?

ផន៖    ហ្នឹងហើយ និងនៅកំពង់ធំប៉ុន្មាននាក់ដែរ ។

វ៉ាស៊ី៖  ក្រចេះស្ទឹងត្រែងកំពង់ធំ ។

ផន៖    ហ្នឹងហើយ ។

វ៉ាស៊ី៖  គេយកមកហ្នឹង គេជ្រើសយកមក ឬយ៉ាងម៉េចនារីអស់ហ្នឹង?

ផន៖    បែបគេហៅតាមស្រុកមក បើប្រវត្តិរូបគេគេយកមកនៅហ្នឹងហើយ ។

វ៉ាស៊ី៖  ប្រវត្តិរូបល្អហ្នឹងប្រវត្តិរូបរបៀបយ៉ាងម៉េច?

ផន៖    យើង ថាយើងធ្វើការឲ្យគេច្បាស់កាលហ្នឹង ។

វ៉ាស៊ី៖  អត់មានជាប់ពាក់ព័ន្ធ?

ផន៖    ដូចមានជាប់ពាក់ព័ន្ធដូចខ្ញុំគេដកគឺបរាចិន ។

វ៉ាស៊ី៖  ចុះពូជាប់ពាក់ព័ន្ធដោយសារគេដកហ្នឹង ដោយសាររឿងខូចសីលធម៌ហ្នឹងមួយទេ?

ផន៖    នេះជីដូនមួយគេបាញ់ចោលនេះ ។

វ៉ាស៊ី៖  អូ ជីដូនមួយពូគេបាញ់ចោល ។

ផន៖    គេវៃចោល ។

វ៉ាស៊ី៖  អ្នកណាជាអ្នកវៃចោល?

ផន៖    ទេ កាលហ្នឹងមិនដឹងណា ឮសូរថា ណាវៃចោល គ្នាឯងគ្មានអាណាទេកាលហ្នឹង ។ ខ្ញុំនៅភ្នំពេញខ្ញុំអត់ដឹងដែរ ។

វ៉ាស៊ី៖  គាត់ធ្វើអីកាលហ្នឹង?

ផន៖    កាលហ្នឹងគាត់ប្រធានភូមិឃុំ  បងភិន ខ្ញុំឈ្មោះហើយ ។

វ៉ាស៊ី៖  ឈ្មោះ ភិន?

ផនៈ ហ្នឹងហើយ គេដក គេអូសចោល....គេលែងទុកចិត្តខ្ញុំ ។ កាលហ្នឹងធ្វើប្រវត្តិរូបមួយថ្ងៃ៣ដង ប្រវត្តិរូបខ្ញុំ ប៉ុនធ្វើខ្ញុំមិនចេញដែរ ។

ភាស៊ីៈ ហៅមកធ្វើប្រវត្តិរូប?

ផនៈ ហ្នឹងហើយ ។

ភាស៊ីៈ កាលហ្នឹងអ្នកណាមក?

ផនៈ បាទ?

ភាស៊ីៈ អ្នកណាអកហៅពូធ្វើប្រវត្តិរូប?

ផនៈ បងហុងហ្នឹង ។

ភាស៊ីៈ អូ ហុង ហ្នឹង?

ផនៈ ហ្នឹងហើយ គាត់នៅក្រសួងការបរទេសគេធ្វើប្រវត្តិប្រវត្តិយើងម៉េចៗ គេដកយើងចេញ

ភាស៊ីៈ ចុះគេវៃបងជីដូនមួយពូ វៃចោលវៃនៅស្រុកអី?

ផនៈ នៅនេះ ។

ភាស៊ីៈ ចុះម៉េចដឹងទៅដល់បងហុងនៅភ្នំពេញនោះ?

ផនៈ ដឹង បើគេរាយការណ៍ពីឃុំទៅ បានគេដឹង ពីស្រុកទៅតាមខ្សែរយៈ ។ ស្តីក៏ដឹងដែរ ។

ភាស៊ីៈ រាយការណ៍ពីណោះទៅ ដឹងដល់នោះហៅពូធ្វើប្រវត្តិរូប?

ផនៈ ធ្វើប្រវត្តិរូប ខ្ញុំក៏មិនដឹងដែរ រយៈពេលមួយភ្លែតហៅ៣ដង ធ្វើប្រវត្តិរូបខ្ញុំក៏ឆ្ងល់ដែរ ។ ប៉ុនថ្ងៃឈប់មួយខ្ញុំយល់សប្តិបាក់ធ្មេញ ខ្ញុំពិចារណាក្នុងចិត្តនៅផ្ទះមានរឿងអី ។ ខ្ញុំក៏សុំមកលេងផ្ទះគេអត់ឲ្យមកទៀត សុំមកលេងផ្ទះគេថាមិនបាច់ទៅទេចាំអាទិត្យក្រោយ ។ ដល់ក្រោយបានដឹង ធ្វើប្រវត្តិរូបបានដឹងហ្នឹង ។

ភាស៊ីៈ គេប្រាប់ពូ ឬពូដឹងខ្លួនឯង?

ផនៈ គេប្រាប់ ។ អាសង់? បងប្អូនជីដូនមួយខ្ញុំដែរ ត្រូវពូវាគេវៃចោល គេយកទៅវៃចោលហើយ ។ ដល់វៃចោលហើយ គេធ្វើប្រវត្តិរូបហើយចឹង ខ្ញុំគេដកមកគាខ្មៅ ។

ភាស៊ីៈ ចឹង មានរឿងផ្ទួនៗគ្នាជាន់គ្នា ។ រឿងសីលធម៌ផង រឿងបងជីដូនមួយពូគេបាញ់ចោលផង កាលហ្នឹងគាត់ជាប់និន្នាការអី ឬក៏គាត់ធ្វើអីខុសបានជាគេបាញ់គាត់ចោល?

ផនៈ ទេ កាលហ្នឹងគេថាដូចរឿងរាយការណ៍អាម៉េចៗទេ រឿងស៊ីចុកម៉េចថាខុះខាតម៉េចទេ ។

រ៉ាស៊ីៈ គាត់រាយការណ៍រឿងហូបចុកម៉េចហ្នឹង?

ផនៈ ដល់នេះគេស្អប់ គេស្អប់ អ្នកដែលធ្វើការផ្ទៃក្នុងដូចគ្នា ។ ដូចបងឯងធ្វើការ៣នាក់ដូចខ្ញុំហ្នឹង បងឯងស្អប់ខ្ញុំ ។ ធ្វើការសំងាត់មួយម៉ាត់ គេធ្វើយើងមួយម៉ាត់ ។

រ៉ាស៊ីៈ ចឹង គ្នាឯងអ្នកបាញ់ចោល?

ផនៈ គ្នាឯង ។

រ៉ាស៊ីៈ ចឹង ដល់ពេលបាញ់ចោល ចុះថ្នាក់លើៗទៅទៀតគិតយ៉ាងម៉េច?

ផនៈ ទេ មិនដឹងគេ វាពិបាកចឹង ខ្ញុំអត់ដឹងផ្ទៃក្នុងរបស់គេ ។

រ៉ាស៊ីៈ ឧទាហរណ៍ធ្វើការ៣នាក់ចឹង ពូបាញ់ពីណាចោលម្នាក់ចឹង ដូចឥឡូវតែហ៊ានបាញ់គេចោលម្នាក់គេចាប់?

ផនៈ យើងមិនបាញ់ទេ ប៉ុនគេអ្នកថាហ្នឹង គេរាយការណ៍ដឹងទេ វាចឹង ។ បងប្អូនខ្ញុំខាងម៉ែឪខ្ញុំគេបាញ់ចោលដែរ?

រ៉ាស៊ីៈ គេបាញ់ចោលដែរ ជំនាន់អាពតហ្នឹង?

ផនៈ ហ្នឹងហើយ ។ ឥឡូវយើងថាវេទនាក៏ពិបាក រស់នៅតាមរបបសង្គមយ៉ាប់ណាស់បងចឹងទេ បងមិនអាចកំណត់មិនឃើញបើយើងអនុវត្តន៍តាមគេ ក៏គេធ្វើយើង វាចឹង ។

រ៉ាស៊ីៈ ចឹង ការងារដែលពូធ្វើហ្នឹងសុទ្ធតែទទួលបញ្ជាគេដែរ?

ផនៈ ទទួលបញ្ជាពីគេ ។

រ៉ាស៊ីៈ ពូនៅចាំទេ តើពូទទួលបញ្ជាពីនរណាហើយឲ្យធ្វើកិច្ចខ្លះ?

ផនៈ ខ្ញុំធ្វើការនៅក្រសួងការបរទេស ទទួលបញ្ជាមានតែពីហុងហ្នឹង គេប្រធានផ្ទាល់ហ្នឹង ។

រ៉ាស៊ីៈ គេបញ្ជាឲ្យពូធ្វើអីខ្លះ?

ផនៈ គេឲ្យយើងធ្វើដូចនៅផ្ទះចឹង គេឲ្យយើងដាំអីនាយអាយ ផ្លែឈើយើងដាំចឹងទៅ ។ ការងារគ្រប់មុខ ។

រ៉ាស៊ីៈ ហឺ ហុងហ្នឹងទទួលបញ្ជាមកពីណាទៀត?

ផនៈ ទេ ហុងមិនដឹងទទួលមកពីណាទេ យើងមិនបានដឹងលំអិតគេ គេអ្នកធំពីលើគេហ្នឹង ។

រ៉ាស៊ីៈ មានអ្នកធំជាអ្នកបញ្ជាមកហុងហ្នឹង ហើយ ហុង ហ្នឹងជាអ្នកបញ្ជាមកដល់ពូ?

ផនៈ ហ្នឹងហើយមកដល់ខ្ញុំទៀតមក ។

វ៉ាស៊ីៈ ហ៊ី ពូបញ្ជារទៅណាទៀត?

ផនៈ ខ្ញុំពុំមានបញ្ជារទៅណាទេ ធ្វើខ្លួនឯងបើយើងជាអ្នក៣-៤គ្នាងចេះធ្វើ គេប្រាប់ឲ្យធ្វើនេះធ្វើនោះៗជូនណាទៅតាមភ្ញៀវៗ

វ៉ាស៊ីៈ ពី ថាទៅតាមភ្ញៀវគេឲ្យទៅតាមភ្ញៀវ?

ផនៈ ហ្នឹងហើយ ។

វ៉ាស៊ីៈ បងហុងហ្នឹងគេឲ្យទៅតាមភ្ញៀវ?

ផនៈ ហ្នឹងហើយ ។

វ៉ាស៊ីៈ ទៅតាមភ្ញៀវក្នុងគោលបំណងអីដែរ?

ផនៈ ចេះដើរតាមគេគេ អាគេអ្នកទៅដល់កំពង់សោមចឹងទៅ យើងទៅតាមគេចឹង ។

វ៉ាស៊ីៈ យើងមានកាន់កាំភ្លើងការពារគេដែរ?

ផនៈ អត់ទេ អត់មានទេ ។

វ៉ាស៊ីៈ គ្រាន់ទៅតាមគេ?

ផនៈ ទៅតាមគេមក ។

វ៉ាស៊ីៈ ភ្ញៀវខស្សរាហមកទេ នៅក្រសួងការបរទេសហ្នឹង ភ្ញៀវបរទេស?

ផនៈ មកដែរ ។

វ៉ាស៊ីៈ មករាល់?

ផនៈ ចេញចូលៗ ។

វ៉ាស៊ីៈ ពូ មានចំណាទេ ភ្ញៀវភាគច្រើនភ្ញៀវមកពីប្រទេសណាដែរ?

ផនៈ កាលហ្នឹងភាគច្រើនកូរ៉េ ។

វ៉ាស៊ីៈ កូរ៉េ?

ផនៈ ហ្នឹងហើយ ចិនក៏មកដែរ ប៉ុន្តែចិនគេមកជួនណា ច្រើនមកកម្មករវា ។

វ៉ាស៊ីៈ ចុះពេលដែលមកហ្នឹងពូមានឃើញអ្នកធំណាខ្លះដែលជូនដំណើរពួកធ្វើទស្សនៈកិច្ច ឬជូនដំណើរពីវាលយន្តហោះមក?

ផនៈ យេឌីញតែបង ហុង ហ្នឹង ហី ក្រៅពីហ្នឹងមិនដឹងពីណាខ្លះមិនសូវស្គាល់គេទេ ។

វ៉ាស៊ីៈ មានឃើញ អៀង សារី អីទេ?

ផនៈ ឃើញដែរ ជួនណាម្តងៗដែរ ។

ព៉ាស៊ីៈ ចុះ ប៉ុល ពត អីឃើញទេ?

ផនៈ ទេ ដូចចន្នោះ ។

ព៉ាស៊ីៈ ចឹង អ្នកធំៗហឹងពូឃើញតែ អៀង សារី មួយទេ?

ផនៈ ហ្នឹងហើយឃើញ ជួនភ្ញៀវច្រើនសារដែរ ។

ព៉ាស៊ីៈ កាលហ្នឹងពូមានឃើញ អៀង សារី ធ្វើអីនៅណា?

ផនៈ ទេ រកកន្លែងកំណត់គោលដៅមិនឃើញ ។ ឃើញនៅនេះតិចនៅនោះតិច ។

ព៉ាស៊ីៈ ពូ ខស្សាហ៍ឃើញនៅក្នុងក្រសួង ខស្សាហ៍ឃើញគាត់ធ្វើការនៅធ្វើការហ្នឹងដែរ?

ផនៈ ជួនណាប្រជុំឃើញគាត់មកដែរចឹងទៅ មិនដឹងគាត់នៅណា មិនដឹង ។

ព៉ាស៊ីៈ ពូ ស្គាល់ប្រពន្ធ អៀង សារីទេ?

ផនៈ អត់ទេ ។.......

ព៉ាស៊ីៈ ចុះភ្ញៀវដែលមកហ្នឹងពេលជួនគេដើរលេងជូនគេទស្សនៈកិច្ចហ្នឹង?

ផនៈ ហ្នឹងជិះឡានតូចទៅជាមួយគេ ។

ព៉ាស៊ីៈ ទៅជាមួយគេហ្នឹង ទៅដល់ណាខ្លះ ពូមានចាំទេ?

ផនៈ ទៅដល់ជួនណាសៀមរាប កំពង់ធំ ក្រចេះ ។

ព៉ាស៊ីៈ គេទៅហ្នឹង គេទៅមើលអីគេ?

ផនៈ ទេ ចេះដើរទៅ គេដើរទស្សនៈកិច្ចមើលប្រទេសខ្មែរយើងកាលហ្នឹង ។

ព៉ាស៊ីៈ ចុះពូថា មានអ្នកបកប្រែឈ្មោះ ធឿន?

ផនៈ ធឿន ។

ព៉ាស៊ីៈ អាយុប្រហែលប៉ុន្មានអ្នកបកប្រែ?

ផនៈ ឥឡូវខ្ទង់បែប៤០ជាងហើយ ។

ព៉ាស៊ីៈ ឥឡូវអត់ដឹងថា គាត់នៅណាទេ?

ផនៈ មិនដឹងទេ ឥឡូវហ្នឹងមិនដឹងនៅណាបាត់ជាង២០ឆ្នាំហើយ អត់មានដឹងទេ ។

ព៉ាស៊ីៈ គេច្រើននិយាយភាសាអី?

ផនៈ ធឿន គេនៅជាមមួយកូរ៉េ ។

វ៉ាស៊ីៈ និយាយភាសាកូរ៉េ ។ ចុះដល់ពេលចិនមកបានពីណាមកប្រែ?

ផនៈ ចិនដូចអាណា ។ ប៉ុនអាណាបែបផាប់ហើយ ។

វណ្ណៈ ពូម៉េចដឹងថាផាប់?

ផនៈ ផាប់ហើយ កាលបាញ់ចាផលិចភ្នំបាសិត អាហ្នឹងដឹងផាប់ហើយ ។

វណ្ណៈ ចុះពូដើរទស្សនៈកិច្ចចិន ពូឃើញថានៅស្រុកខ្មែរយើងតាមផ្លូវមានសភាពស្ងាត់ឬមានមនុស្សអ៊ូអ៊រ ទៅអង្គរវត្តមានសភាពយ៉ាងម៉េចដែរ?

ផនៈ ទេ កាលហ្នឹងមនុស្សច្រើនដែរ មានអត់មនុស្សណា មនុស្សច្រើននៅតាមផ្លូវ ។ មានខ្វាចអីទេកាលហ្នឹង ។

វណ្ណៈ ចង់និយាយថាប្រជាជន ប្រជាជនចុះទៅធ្វើស្រែស្ងាត់ភូមិឬមានប្រជាជន នៅតាមផ្លូវអឺអ៊ូអរច្រើន?

ផនៈ ដូចឥឡូវហ្នឹង ។

វណ្ណៈ ចុះនៅក្នុងភ្នំពេញមានសភាពម៉េចដែរ?

ផនៈ កាលនោះភ្នំពេញ កាលខ្ញុំនៅទេដូចសភាពអី កាលហ្នឹងគ្មានប្រជាជននៅទេ មានតែជំនាញការវៀតណាម ទ័ពខ្មែរយើង មានកម្មករ មាននារីបោសសំអាតនៅភ្នំពេញហ្នឹង ។

វណ្ណៈ នៅឆ្នាំណាមានជំនាញការវៀតណាម?

ផនៈ ជំនាញការវៀតណាមនៅភំពេញតាំងពីឆ្នាំ១៩៧៥ ។

វ៉ាស៊ីៈ ឆ្នាំ១៩៧៥មានជំនាញការវៀតណាម?

ផនៈ បាទ!

វ៉ាស៊ីៈ ពូម៉ិញមានប្រសាសន៍ថា ថាមានស្ថានទូតវៀតណាម?

ផនៈ មាន ។

វ៉ាស៊ីៈ មានទីតាមងនៅណាស្ថានទូតវៀតណាម?

ផនៈ នៅខាងលិចចំការមន មិនដឹងផ្ទះលេខប៉ុន្មានទេភ្លេចទៅកាលហ្នឹង ។

វ៉ាស៊ីៈ ខាងលិចចំការមន?

ផនៈ បាទ!

វ៉ាស៊ីៈ ចុះចិនអីមានស្ថានទូតទេ?

ផន៖ មាន ។

រ៉ាស៊ី៖ កូរ៉េមានដែរ?

ផន៖ មានទាំងអស់ គេឲ្យផ្ទះមួយៗ ។

រ៉ាស៊ី៖ ចុះពេលចូលប្រជុំម្ដងៗពូមានដឹងថា មានវៀតណាមអីចូលទេ?

ផន៖ មកដែរហ្នឹង ។

រ៉ាស៊ី៖ ឆ្នាំណាបានស្ដានទូតវៀតណាមដកចេញ?

ផន៖ ដូចឆ្នាំ១៩៧៦ ខែ៦ ។

រ៉ាស៊ី៖ ខែ៦ ឆ្នាំ១៩៧៦?

ផន៖ ហ្នឹងហើយ ។

រ៉ាស៊ី៖ ដកស្ដានទូតវៀតណាមចូលដោយសារមូលហេតុអី?

ផន៖ ទេ កាលហ្នឹងអ្នកឡុកវៃចូលហ្នឹង ។ វៀតណាមវៃចូលកាលហ្នឹង ។

រ៉ាស៊ី៖ វៃចូលកាលហ្នឹង?

វណ្ណៈ វៃចូលខាងណាវៃចូលនៅ?

ផន៖ វៃចូលភ្នំពេញហ្នឹងវៃចូលលើកទី២ហ្នឹង ។ អ្នកមិនដឹងមិនដឹងទេ កាលវៀតណាមវៃរំដោះយើងកាលហ្នឹង ។ រំដោះនៅភ្នំពេញហ្នឹង ។

រ៉ាស៊ី៖ ពូ កាលធ្វើទ័ពបន្ទាប់ពូចេញពីដាំស្ពៃ៨ខែនៅតាខ្មៅនៅកងពល១២ហ្នឹង?

ផន៖ ហ្នឹងហើយ ។

រ៉ាស៊ី៖ ពូ ធ្វើនៅហ្នឹងរហូតទើសបែកហ្មង?

ផន៖ អត់ទេ កាលចូលក្រោយអាហ្នឹង កាលនៅក្រសួងការបរទេស ដល់ពេលខុស គេដកទៅនៅដាំស្ពៃរយៈពេល៨ខែ ស្ដាប់បានទេ ។ ដល់ពេលវៀតណាមបុកចូលគឺប ខ្ញុំក៏រត់ទៅ ។

រ៉ាស៊ី៖ អូ ពូរត់ទេ?

ផន៖ រត់ទៅនៅកងពល១២ហ្នឹង ។

រ៉ាស៊ី៖ ទៅនៅកងពល១២ កាលហ្នឹងកងពលរបស់ខ្មែរក្រហមដែរ?

ផន៖ ខ្មែរក្រហមកាលហ្នឹង ។

រ៉ាស៊ី៖ ពូ មានបាននៅរៀនក្បួនយុទ្ធសាស្ត្រ ទៅធ្វើការនៅទាហានហ្នឹង?

ផនៈ	វៀនតែវៃនោយអាយហ្នឹងកាលហ្នឹង ។

ភ៉ស៊ីៈ	ចុះពូរត់ទៅ គេអត់ថាអីទេកាលនេះហ្នឹង រត់ពីនេះទៅចូលនោះចឹង?

ផនៈ	គេមានថាអីកាលហ្នឹង វៀនទៅទប់ទល់វៀតណាមវិញហ្នឹង ។ កាលហ្នឹងមិនដឹង ។

ភ៉ស៊ីៈ	កាលហ្នឹងចេះចាប់ញាត់ៗ?

ផនៈ	ហ្នឹងហើយចេះចាប់ញាត់ៗ ។...............?

ភ៉ស៊ីៈ	កងពល១២ នៅណា?

ផនៈ	កាលហ្នឹងនៅខាងលិចភ្នំពេញ ។

ភ៉ស៊ីៈ	ខាងលិចភ្នំពេញ?

ផនៈ	ហ្នឹងហើយ ដល់ពេលដកពីបទៅត្រៀមនៅក្បែរភ្នំបាសិត ហើយចេញទៅដល់ពេលដល់ ឱរ៉ាល់បែកគ្នាគឺប ។

ភ៉ស៊ីៈ	ដល់ឱរ៉ាល់បែកគ្នា?

ផនៈ	បែកអស់អាលឹង ។

ភ៉ស៊ីៈ	បែកម៉េច បែកវៀតណាមវៃ?

ផនៈ	វៀតណាមវៃបែកខ្ទេចអស់ ។

ភ៉ស៊ីៈ	កាលហ្នឹងឆ្នាំ១៩៧៩?

ផនៈ	ហ្នឹងហើយ ។

ភ៉ស៊ីៈ	ចឹង ពូធ្វើនៅកងពល១២ហ្នឹងបានប៉ុន្មានដែរ ច្រើនដែរ?

ផនៈ	ទេ ច្រើនណាស់មួយខែ ។ ចុះកាលហ្នឹងពេល វៀតណាមនបុកចូល យើងត្រូវគេ ចាប់បញ្ចូលពីបៗ យកមកវៃវិញ ។ ដល់ពេលវិញ ពួកនេះដកៗដល់ភ្នំបាសិតដល់ភ្នំឱរ៉ាល់បែកក្តាំងរត់របាត់របាយទៅ ។

ភ៉ស៊ីៈ	ចឹង ពូមានប្រសាសន៍មិញថា ពួគេដកទៅនៅតាខ្មៅហ្នឹងចុងឆ្នាំ១៩៧៥?

ផនៈ	ហ្នឹងហើយ ។

ភ៉ស៊ីៈ	មិញពូមានប្រសាសន៍ថា ទៅនៅកងពល១២ហ្នឹង អត់បានមួយខែផងបែកភ្នំពេញ បែកឆ្នាំ១៩៧៩?

ផនៈ	បាទ!

រ៉ាស៊ីៈ ចុះម៉េចរយៈពេលខុសគ្នាច្រើនម៉េសពូ?

ផនៈ ខុសគ្នាច្រើន ។

រ៉ាស៊ីៈ ខ្ញុំថាពូធ្វើការនៅក្រសួងការបរទេសបានច្រើនឆ្នាំដែរ អត់ទេ?

ផនៈ ច្រើនឆ្នាំដែរ ដល់ខ្ញុំមកនេះមក ។ ដល់មានកំហុស បានគេកមកដាក់មន្ទីរ យូរដែរ ។

រ៉ាស៊ីៈ យូរដែរ?

ផនៈ ហ្នឹងហើយ ពិបាកណាស់រកកំត់ចំណាំមិនឃើញ យើងមិនបានកត់ចំណាំទុក អាចយើងនិយាយមិនអស វាច្រឡំដែរហ្នឹង ។

រ៉ាស៊ីៈ ពូ អត់ចាំដែរ?

ផនៈ ហ្នឹងហើយ ។

រ៉ាស៊ីៈ បើតាមពូនិយាយមក ខ្ញុំថាពូធ្វើនៅហ្នឹងពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៨ នៅក្រសួងការបរទេស?

ផនៈ ហ្នឹងហើយខ្ទង់ប៉ុណ្ណឹង ។

រ៉ាស៊ីៈ ខ្ទង់ប៉ុណ្ណឹង?

ផនៈ ហ្នឹងហើយដល់យួនបុកចូលមកបានបែកគ្នា ។ ដល់បែកគ្នាទៅរៀបទ័ពហ្នុង ។ គេចាប់ផ្ទុកៗហ្នុង ។

រ៉ាស៊ីៈ ចុះពូមានទៅវៃជាមួយវៀតណាមទេ?

ផនៈ បានវៃដែរធ្វើម៉េចវៃមួយឆាវៗដកវិញទេ ។

រ៉ាស៊ីៈ វៃដកៗ?

ផនៈ បាទ!

រ៉ាស៊ីៈ ចុះឆ្នាំណាបានពូមកដលស្រុកកំណើតវិញ?

ផនៈ ឆ្នាំ១៩៧៩ ទេមើលឆ្នាំ១៩៧៩ ដាច់ហ្នឹង មកដល់បានប៉ុន្មានខែបានការប្រពន្ធ ។

រ៉ាស៊ីៈ មកដល់ស្រុកនៅនេះអត់មានពីណាថាអីទេ អត់មានអ្នកណារករឿងអីទេ?

ផនៈ អត់ទេ ខ្ញុំគ្មានធ្វើសកម្មភាពអី អត់មានទេ សួរបងមើល ។

រ៉ាស៊ីៈ យើងមនុស្សល្អ?

ផនៈ ហ្នឹងហើយ ។ ពីរបីប្រវត្តិដែលយើងវេទនាខ្ញុំអត់ទេ ព្រោះខ្ញុំស្លូតខ្ញុំធ្វើការត្រង់ ។ សួរភូមិមើលមិនដែលស្អប់ខ្ញុំខ្ញុំមិនដែលអុកឡុកគេអត់ទេ ។

រ៉ាស៊ីៈ ពូ នារីធីហ្នឹងរហូតដល់សព្វថ្ងៃ ពូមានដឹងថា គាត់ស្លាប់ឬរស់?

ផនៈ បែបស្លាប់ហើយតាមមើល ព្រោះខ្ញុំចេញពីនោះមកខ្ញុំអត់ឃើញផង ។

រ៉ាស៊ីៈ ពេលដែលគេចាប់ពូទៅជាំស្លែ៨ខែហ្នឹងគេចាប់តែពូទៅ គេអត់ចាប់ធីទៅជាមួយទេ??

ផនៈ អត់ទេ ។ ទាល់បានមួយខែបានគេយកប្រពន្ធខ្ញុំទៅ ។

រ៉ាស៊ីៈ កាលហ្នឹងគាត់ធ្វើការនៅក្នុងក្រសួងការបរទេសដែរ?

ផនៈ នៅក្រសួងការបរទេសដែរ ។

រ៉ាស៊ីៈ គាត់នៅផ្នែកជាមួយដែរអត់ទេ?

ផនៈ គេនៅខុសមន្ទីរខ្ញុំ ដល់ពេលទៅប្រជុំទៅការផ្សារឆ្ងាយជួនណាធ្វើដំណើរទៅជាមួយគ្នា ។

រ៉ាស៊ីៈ ចឹង បានកើតហេតុស្រឡាញ់គ្នាទៅ ។

វណ្ណៈ កាលហ្នឹងពូអាយុប៉ុន្មាន?

ផនៈ ខ្ញុំកាលមើល កាលចេញពីផ្ទះទៅអាយុ១៦-១៧ ខ្ញុំធំដែរហើយ ដល់ទៅភ្នំពេញមិនដឹងអាយុប៉ុន្មានទេ មិនដល់២០ទេ ។

រ៉ាស៊ីៈ កាលនៅស្រុក ពូនៅនិរសាស្រុក រត់ពីស្រុកមកឃុំ?

ផនៈ ហ្នឹងហើយ ចុះឡើងទៅកន្លែងទ័ពហ្នឹងទៅ ។ ទៅខ្សែត្រៀមមុខ ដល់គេត្រូវការ ។

រ៉ាស៊ីៈ ចុះនិរសាដែលគួររត់ សំបុត្រដែលគួរត់ហ្នឹង គេបិទជិតឬក៏មាន?

ផនៈ គេបិទជិតឈឹង ។

រ៉ាស៊ីៈ ពូ អត់ដឹងពីអត្ថន័យនៅខាងក្នុង?

ផនៈ អត់ដឹងទេ ។

រ៉ាស៊ីៈ ពូមានសង្ស័យចង់ហែកមើលទេ?

ផនៈ អត់ហ៊ានទេ ដល់ហើយសង្ស័យហែកម្តង ស្តីឲ្យ ហែកមើល ។

រ៉ាស៊ីៈ គេសរសេរថាម៉េច?

ផនៈ កាលហ្នឹងគេសរសេរថាទៅចាប់អាណាទេ ចាប់អាណាទេ ហែកមើលរបស់គេ ដល់ហើយគេខឹងខ្ញុំ បានគេដកខ្ញុំទៅភ្នំពេញហ្នឹង ។

រ៉ាស៊ីៈ អូ ចឹងដកពូទៅភ្នំពេញដោយសារពូលួចហែកសំបុត្រមើល?

ផនៈ ហ្នឹងហើយ ខ្ញុំខិលដែរកាលហ្នឹង ។

រ៉ាស៊ីៈ អូ ចឹងគាសៀង គាសានហ្នឹគាត់ផ្ញើសំបុត្រតាមពូទៅឲ្យទៅចាប់ពីណាម្នាក់នៅក្នុងភូមិដែលពូមើលហែកសំបុត្រហ្នឹង?

ផនៈ ហៅអាណា ហៅមក គេថាចឹង គេហៅមកគេដាក់ចឹង យើងថាស្មានទេ ការងារផ្ទៃក្នុងរបស់គេដល់គេហៅមកគេសួរស្ងាត់ចឹង ។

វណ្ណៈ ចុះរយៈពេលដែលពូទៅនៅភ្នំពេញហ្នឹងពូមានដែលឃើញសកម្មភាពអី ការចាប់មនុស្សឬក៏មនុស្សខុសដោយសារអីអ៊ីមួយគេចាប់យកទៅ ពូមានដែលឃើញទេ?

ផនៈ ជួនណាគេមានដែរ មានដែលនៅក្នុងមន្ទីរ គេថាប៉ះពាល់នយោបាយគេចាប់ ។

រ៉ាស៊ីៈ មានដែលនៅក្នុងមន្ទីរ ប៉ះពាល់នយោបាយយ៉ាងម៉េច?

ផនៈ យើងនៅជាមួយគ្នាយើងនិយាយអី មានអ្នកចាប់ថ្នាក់គេចាប់យើងចឹងទៅជួនណា វាពិបាកការងារច្រើនជួនណាយើងដើរហើរជាមួយគេ មានគេអ្នកតាមដានយើង យើងមិនពេញចិត្តគេ វាពិបាកណាស់ ជួនណាគេរាយការណ៍ស្ងាត់ចឹង ។

រ៉ាស៊ីៈ ចឹងបានន័យថាក្នុងចំណោមមនុស្សពីរនាក់សុទ្ធតែមានជនបង្កប់ មានអ្នកបង្កប់?

ផនៈ មានអ្នកបង្កប់តាមដានគ្នាទៅវិញទៅមក ។ ខ្ញុំ ម៉េចដូចគេ ។

រ៉ាស៊ីៈ ចុះពូមានធ្លាប់ទទួលបញ្ជាពីប្រធានពូឲ្យមកតាមដានពីអ្នកណាម្នាក់នៅក្នុង?

ផនៈ អត់មានទេ មានតែអាភៀងទេ ជាអ្នកតាមដាន ។

រ៉ាស៊ីៈ មានដឹងគាត់ទទួបញ្ជាពីណាមកទេតាមដាន?

ផនៈ ពីបងហុងហ្នឹង ។

រ៉ាស៊ីៈ ពីបងហុងដែរ ចឹងសូម្បីតែ ឧទាហរណ៍គាត់អ្នកបង្រៀនពូ ពូជាកូនសិស្សរបស់គាត់សូម្បីតែកូនសិស្សខ្លួនឯងក៏អត់ទុកចិត្តដែរ មានជនបង្កប់សំរាប់តាមដាន?

ផនៈ អត់ទុកចិត្ត ។ សំខាន់ន័យនយោបាយរបស់គេខ្លាចប៉ះពាល់ភ្ញៀវនិយាយស្តី ។

រ៉ាស៊ីៈ ប៉ុនពូអត់ ដែលធ្វើអីឲ្យប៉ះពាល់ភ្ញៀវទេ?

ផនៈ អត់ទេ ។ មិននិយាយទេ ការងារនេះខ្ញុំមិននិយាយទេ គេប្រើឲ្យវែកអាចម៍វែកអាចម៍រហូត

ដាំស្ពដាំស្ពៃរហូត ។ បើថានៅទាហានអី គេប្រើខ្ញុំឲ្យឡើងវៃ មិនស្រួលខ្ញុំមិនឡើងវៃទៀត អត់ឡើង ។ បើធម្មតាអាចប្រើបាន ។

រ៉ាស៊ីៈ ពូ នៅទាហានធ្វើអីដែរ?

ផនៈ អត់មានធ្វើអីទេ ធ្វើប្រធានក្រុមហ្នឹង ។ កាលហ្នឹងមានអីយើងនៅក្មេងដែរ ។

រ៉ាស៊ីៈ ប្រធានក្រុមមានកាំភ្លើងខ្លីកាន់ទេ?

ផនៈ អត់មានទេ ។ ធម្មតាដូចយើងយុទ្ធជនដូចគ្នាហ្នឹង អើគ្រាន់ថាទៅមុខអីយើងមានដឹកនាំគេ ទៅវិញទៅមក ។

រ៉ាស៊ីៈ ពូ នៅក្នុងរបបខ្មែរក្រហម ៣ឆ្នាំជាងហ្នឹង ពូមានដែលឃើញនរណាម្នាក់សម្លាប់មនុស្ស ទេ?

ផនៈ មានដែរ ឃើញអ្នកសំលាប់ ។

រ៉ាស៊ីៈ មានដែរ ពូមានឃើញផ្ទាល់ភ្នែកទេ?

ផនៈ ហ្នឹងហើយ ។ ពិបាកណាស់សង្គមចឹង គេប្រើយើងធ្វើ យើងមិនធ្វើមិនកើត ។

រ៉ាស៊ីៈ គេប្រើពូធ្វើហ្នុង?

ផនៈ ទេ ខ្ញុំអត់ដែលទេ ។

រ៉ាស៊ីៈ នរណាគេអ្នកធ្វើ?

ផនៈ មានតែអាភឿនហ្នឹង ។

រ៉ាស៊ីៈ អាភឿន ចាប់ខ្ញុំហ្នឹង ។ វាចាប់ វាវៃ ……គេថាវាចាប់ទៅព្រៃសរ……. ។

វណ្ណៈ ចុះពូមានដែលឮថាមានគុកក្រៅពីពៃសរទេ?

ផនៈ អត់ទេ ។ គេថាដើងចាស់ម៉េចទេ ខ្ញុំមិនស្គាល់ដែរ ។

វណ្ណះៈ ចុះទួលស្លែង ពូដេលឮទេ?

ផនៈ ដែលឮ ទួលស្លែងខ្ញុំដែលឮ ខ្ញុំមិនស្គាល់ជាតិទេ ។

រ៉ាស៊ីៈ ពូថាឃើញគេសំលាប់មនុស្ស ភឿន ហ្នឹងជាអ្នកសំលាប់?

ផនៈ ឃើញគេចាប់ចងទៅ មិនដឹងគេសំលាប់អត់ឃើញនឹងភ្នែកទេ ។

រ៉ាស៊ីៈ អូ អត់ឃើញគេសំលាប់គេ គ្រាន់ឃើញគេចងទៅ?

ផនៈ បាទ! ។

រ៉ាស៊ីៈ ចាប់មនុស្សយកទៅព្រៃសរ?

ផនៈ បាទ!

រ៉ាស៊ីៈ ពូ មានដឹងថា អ្នកដែលចាប់ហ្នឹងជនរងគ្រោះហ្នឹងមានទោសអីទេ?

ផនៈ មិនដឹង គេមិនប្រាប់យើងទេ ចាប់យើងគេថាយើងខ្ជិលការងារចឹង ណាមួយគេឃើញយើង គេរាយការណ៍ទៅ ។ វាពិបាកតាមដានណាស់ ។ នេះផ្ទះនេះ ។

រ៉ាស៊ីៈ ឃើញនៅពេលណាដែរ?

ផនៈ កាលខ្ញុំឃើញយូរដែរ មិនដឹងឆ្នាំប៉ុន្មាន កាលនៅក្រសួងការបរទេសហ្នឹង ។ ខ្ញុំប្រាប់មិញអាចដឹង ។

រ៉ាស៊ីៈ ឃើញនៅភ្នំពេញដែរ?

ផនៈ ហ្នឹងហើយ ។

រ៉ាស៊ីៈ នៅភ្នំពេញនៅត្រង់ណាដែរពូ?

ផនៈ នៅខងលិចចំការមន ផ្ទះលេខ គេដាក់ផ្ទះលេខមួយចឹងទៅ ប១ចឹងទៅ មិនដូចយើងឥឡូវពិបាកហៅ ។

រ៉ាស៊ីៈ អត់ដឹងប១ តើ ពាក្យពេញថាម៉េចទេ?

ផនៈ ហ្នឹងហើយ ប្រវត្តិនោះគេហៅមក ។

រ៉ាស៊ីៈ ពូ ឃើញតែម្តងហ្នឹងទេ?

ផនៈ តែម្តងហ្នឹង ។

រ៉ាស៊ីៈ ចុះជនរងគ្រោះឈ្មោះអីដែលពូឃើញហ្នឹង?

ផនៈ ធឿន ។

រ៉ាស៊ីៈ ធឿនអ្នកបកប្រែហ្នឹង?

ផនៈ មិនមែនទេ ធឿនមួយទៀត គេចាប់ ។

រ៉ាស៊ីៈ ចុះ ការធ្វើទារុណកម្មអីពូមានដែលឃើញទេ គេធ្វើទារុណកម្មទេ?

ផនៈ អត់ទេ រឿងនៅគេ គេហៅទៅយើងមិនដឹងរឿងគេ គេមិនប្រាប់យើងទេ យើងខុសយើងនឹកមិនឃើញ ជួនណាយើងកាប់នេះបាក់ចបចឹងទៅធេវីនេះខូចខតទៅប្រធានគេរាយការណ៍យើងអត់ដឹងទេ ដល់ពេលគេមកចាប់យើងអត់ដឹងទេ រឿងវាចឹង ។

រ៉ាស៊ីៈ ចុះពូធ្វើការនៅហឹង ហើពូធ្លាប់បានជិះឡានជូនភ្ញៀវអី ពូមានដែលឃើញវត្តអារាមទីកន្លែង មន្ទីរអីមួយធំៗដែលគេវៃចោល?

ផនៈ ដូចអត់ឃើញកាលហ្នឹង ឃើញឃ្លាំងគេដុតចោលដែរកាលហ្នឹង ។

រ៉ាស៊ីៈ ធ្លប់ឃើញឃ្លាំងគេដុតចោលដែរ?

ផនៈ ហ្នឹងហើយ ។

រ៉ាស៊ីៈ ឃ្លាំងអីគេ គេដុតចោល?

ផនៈ ឃ្លាំងអង្ករ ។

រ៉ាស៊ីៈ ពួកណាដុត?

ផនៈ មិនដឹងពួកណាយើងមិនដឹង ។

រ៉ាស៊ីៈ ពូ មានដែលសង្កេតឃើញថាមានលោកមានអីទេ កាលជំនាន់ហ្នឹង?

ផនៈ អត់មានទេ ។ មិនដែលឃើញទេ ចំពោះខ្ញុំមិនឃើញដើរអត់មានចន្លោះជួបទេ ។

រ៉ាស៊ីៈ ពូ ធ្វើការនៅក្រសួងការបរទេសហ្នឹង គេឲ្យពូទៅស្នាក់នៅណាដែរ?

ផនៈ ខ្ញុំនៅភ្នំពេញ ។

រ៉ាស៊ីៈ នៅក្បែរក្រសួងហ្នឹងដែរ?

ផនៈ ហ្នឹងហើយ ។ ផ្ទះក្បែរភ្ញៀវ ។

រ៉ាស៊ីៈ ចុះវត្តអារាមផ្សេងៗពូមានដែលឃើញសភាពយ៉ាងម៉េចដែរ?

ផនៈ ទេ គ្មានឃើញអី មានតែវៃចោលវត្ត ។

រ៉ាស៊ីៈ វត្តគេវៃចោលដែរ?

ផនៈ បាទ!

រ៉ាស៊ីៈ អ្នកខាងណាវៃចោល?

ផនៈ ទេ កាលហ្នឹងមានតែរបបហ្នឹង មានរបបណាទៀត ។

រ៉ាស៊ីៈ មានតែរបប ប៉ុល ពត ហ្នឹង?

ផនៈ ហ្នឹងហើយ ។

រ៉ាស៊ីៈ គេវៃចោលក្នុងបំណងអីដែរពូ?

ផនៈ ទេ មិនដឹងគេទំលាយចោលព្រះពុទ្ធសាសនាឬមិនដឹងអាម៉េចគេ ។

វ៉ាស៊ីៈ គេមានផែនការ?

ផនៈ ហ្នឹងហើយគេមានផែនការ គេមិនប្រាប់យើងផ្ទៃក្នុងរបស់គេ ។

វ៉ាស៊ីៈ ពូ យល់យ៉ាងម៉េចដែររបបខ្មែរក្រហម ចិត្តរបស់ពូ?

ផនៈ ទេ អារម្មណ៍ថាឲ្យវា រឿងវេទនា វេទនាហើយម៉ែឪនៅផ្ទះ យើងទៅមុខក៏វេទនាដូចគ្នា អារម្មណ៍ទី១ខ្លាចគេចាប់ចងវៃចោលអារម្មណ៍ទី២ការងារគេមិនទុកចិត្តយើងពិបាកសន្និដ្ឋាន ណាស់ការរស់នៅ

វ៉ាស៊ីៈ ពូ មានអារម្មណ៍ថាចឹង ឲ្យមានរបបហ្នឹងកើតឡើងវិញ ឬក៏យ៉ាងម៉េច?

ផនៈ ចិត្តរាល់ថ្ងៃ?

វ៉ាស៊ីៈ បាទ!

ផនៈ អត់ទេ ។ ថាម៉េចយើងមិនអាចមើលចិត្តគេម្នាក់ៗ តែចំពោះយើងខ្ញុំបានប៉ុណ្ណឹងវាស្រួល បើរៀបបានស្រួលជាងហ្នឹងទៀតក៏អរ ។

វ៉ាស៊ីៈ ជំនាន់នេះ?

ផនៈ ហ្នឹងហើយ ។

វ៉ាស៊ីៈ ម៉េចបានជាពូ អត់ចង់ឲ្យមានរបបប៉ុល ពត របបខ្មែរក្រហម?

ផនៈ ទេ ក្រែងវាពិបាកណាស់ មិនហ៊ានអារកាត់ទេ ព្រោះខ្ញុំអ្នកល្ងង់ដែរវាពិបាកណាស់ ។

វ៉ាស៊ីៈ ពូ អ្នកធ្វើការនៅក្នុងរបបហ្នឹងដែរ ពូមានដឹងថា របបហ្នឹងមានសំលាប់មនុស្សដែរ ឬអត់ទេ?

ផនៈ មាន ។

វ៉ាស៊ីៈ ពូដឹងដែរ?

ផនៈ ដឹង ។

វ៉ាស៊ីៈ ពូ ដឹងដោយអារម្មណ៍ខ្លួនឯង ឬមានដោយសារគេនិយាយ?

ផនៈ អារម្មណ៍ពុស្សូរគេនិយាយ គេនឹងភ្នែកក៏ឃើញ អាហ្នឹងឃើញនឹងភ្នែកគេដឹកយកទៅចឹងទេ ។ ការរស់នៅវាពិបាក ដូចបងឯងរស់នៅសព្វថ្ងៃចឹង ការងារគេរាល់ថ្ងៃដល់ពេលយ៉ាប់ទៅ យើងដឹងចឹងផង ។ វាពិបាកណាស់ ផ្ទៃក្នុងរបស់គេមិនប្រាប់យើងណា ហីយើងម៉េចដឹង

នយោបាយនៅក្នុងសង្គមនីមួយៗមិនអាចដឹងបានទេ ខ្ញុំក៏ដឹងមិនបានដែរ ។ បងឯង យល់ហើយ អាហ្នឹងហើយ ចំពោះខ្ញុំអត់ដឹងទេ លួងសុទ្ធ ។ គេឲ្យធ្វើអីធ្វើហឹង ។

រ៉ាស៊ីៈ កាលពូធ្វើការនៅក្នុងរបបជាមួយប៉ុលពតហ្នឹង កាលហ្នឹងពូពេញចិត្តហ្នឹង ការងារនឹងពូធ្វើហ្នឹងទេ?

ផនៈ ទេ ថាពេញចិត្តក៏បាន មិនថាក៏បាន ចំពោះខ្លួនខ្ញុំអើ បើការងារប៉ុណ្ណឹងអាចទៅបាន វាវេទនា វេទនារឿងស៊ីចុក វេទនាហើយ ឥឡូវបើយើងមិនធ្វើវាពិបាកចិត្ត ។

រ៉ាស៊ីៈ បើយើងមិនធ្វើដេកអត់ស្រណុក រឿងហ្នឹងវាចឹង?

ផនៈ រឿងហ្នឹងវាចឹង ។

រ៉ាស៊ីៈ ពូ ថា ពូអត់ចង់បានរបបហ្នឹង តើពូចង់ឲ្យក្មេងៗដឹងពីទុក្ខវេទនានៅក្នុងរបបហ្នឹងទេ ក្មេងៗជំនាន់ក្រោយនេះ តើចង់ឲ្យវាដឹងថា ជីវិតយើងតស៊ូនៅក្នុងរបបហ្នឹង វាពិបាកយ៉ាងម៉េចៗ មានចង់ឲ្យមានដឹងទេ?

ផនៈ ចង់ឲ្យវាដឹងដែរ ។

រ៉ាស៊ីៈ ក្នុងបំណងអីដែរ ចង់ឲ្យវាដឹងដើម្បីអី?

ផនៈ ចង់ឲ្យវាដឹងថា កាលពីជំនាន់ខ្ញុំសង្គមនោះវាពិបាកវាវេទនា វាខ្លាំងពេក ដូចថាបានផ្ទះជ្រកឬមួយឲ្យបានហ្នឹងទេ តែដំណាក់កាលឥឡូវនេះបានស្រួលចង់ឲ្យវា ប្រាប់វាថា អញពិបាកសំបើមណាស់ កាលនៅ លួហ្អែងបានស្រួលប៉ុណ្ណឹង រឿងហ្នឹងម៉ាសង្គមៗវាតែងពិបាកមួយចំណុចៗមានហើយ ។ វាវេទនាកាលឆ្លងកាត់រស់នៅវាយ៉ាប់ហើយ ។

រ៉ាស៊ីៈ ពូ មានដែលនិយាយពីប្រវត្តិរបស់ពូ ដូចពូនិយាយប្រាប់ខ្ញុំមានដែលនិយាយប្រាប់ក្មេងៗឬបងប្អូនសាច់ញាតិអីទេ?

ផនៈ ប្រាប់ដែរ វាអាចដឹងដែរ ។

រ៉ាស៊ីៈ ពូ យល់ថាប្រវត្តិរបស់ពូហ្នឹងយ៉ាងម៉េចដែរ.

ផនៈ ប្រវត្តិហ្នឹងវាយ៉ាប់ណាស់អញ ប្រាប់វាចឹង ។

រ៉ាស៊ីៈ ប្រាប់ថាយ៉ាប់?

ផនៈ យ៉ាប់ ។

រ៉ាស៊ីៈ តើមានចង់ឲ្យវាយកគំរូតាមពូ ឬមិនចង់?

ផន៖ មិនចង់ឲ្យយកទេ ។

រ៉ាស៊ី៖ ចុះពូចង់ឲ្យមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមទេ អ្នកធំៗដែលពូធ្លាប់ស្គាល់ទាំងប៉ុន្មានដូច ប៉ុល ពត អៀងសារីអី?

ផន៖ ឥឡូវពិបាកណាស់ អាកាត់មិនបាន ។

រ៉ាស៊ី៖ តែក្នុងចិត្តរបស់ពូចង់ទេ តើចង់ឲ្យកាត់ទោសពួកហ្នឹងទេ?

ផន៖ ទេ ខ្ញុំពិបាកសន្និដ្ឋាន មិនហ៊ាននិយាយទេ ។

វណ្ណះ៖ អត់អីទេ ជាមតិយោបល់របស់ពូ បើពូមានរបសាសន៍ក៏មិនអីដែរស្រេចចិត្តពូ?

រ៉ាស៊ី៖ នៅក្នុងកំឡុងពូធ្វើការ តើពូមានដែលបានស្ដាប់រ៉ាត់យោទេ?

ផន៖ កាលហ្នឹងគ្មានរ៉ាត់យោស្ដាប់ទេ ។ មិនសូវមានស្ដាប់ទេ ។

រ៉ាស៊ី៖ ចុះមានដែលអាន ឬក៏គេអានឲ្យស្ដាប់ពីសន្ទរកថារបស់មេដឹកនាំធំៗ ?

ផន៖ ជួនណាគេហៅប្រជុំឲ្យស្ដាប់ដែរ ប៉ិនខ្ញុំភ្លេចអស់ហើយ ។

រ៉ាស៊ី៖ សន្ទរកថាគេ គេនិយាយអីអីខ្លះ?

ផន៖ គេនិយាយពីការងារយើងធ្វើអ៊ីមួយឲ្យស្មោះត្រង់ ឲ្យយើងស្មោះត្រង់នឹងគេកិច្ចការនៅជាមួយគ្នៀវហ្នឹងតើធ្វើម៉េច ការនិយាយស្ដីកុំឲ្យខុសប្រយ័ត្ន ។ គេប្រាប់ចឹងដែរ ។

រ៉ាស៊ី៖ គេប្រាប់ចឹង អត់មានសន្ទរកថាអី ដាក់ចេញជាអនុក្រិត្យឲ្យមានសំលាប់មនុស្ស ឬសំលាប់ជនជាតិអីដែលធ្វើខុសពីគោលនយោបាយរបស់គេទេ?

ផន៖ គេអត់មានប្រកាសទេ អាហ្នឹង ។ អត់មានទេ ការងារផ្ទៃក្នុងរបស់គេ បានដឹង ខ្ញុំអត់ដឹងទេ ។

រ៉ាស៊ី៖ ពូមានអីចង់បន្ថែមទៀតទេ?

ផន៖ ខ្ញុំគ្មានទេ អស់ហើយ ។

រ៉ាស៊ី៖ ចឹង ខ្ញុំអរគុណពូច្រើន ។

ចប់